February-2009.qxd 1/24/2009 4:38 PM Page 1

CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី២ ថ្ងៃទី០១-២៨ ខែកុម្ភៈ ឆ្នាំ២០០៩ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ

លេខ ១៨

### មាតិកា



ឈី ហៀន : "ជួយសង្គម និងអ្នកក្រីក្រជា..."
ទំព័រ ៧



សមាគមសិប្បកម្មជម្នះភាពទុក្ខលំបាករបស់...
ទំព័រ ៨



មាឃបូជា រំឭកមហាសន្និបាត...
ទំព័រ ១៤

# ឆ្នាំថ្មីហើយ! ទីផ្សារអចលនទ្រព្យកម្ពុជានៅតែជាប់គាំង

ទំព័រទី១០_១១



SIPAR
សៀវភៅ
ធ្វើអោយអ្នកចេះ
មានលក់នៅតាមបណ្ណាគារ
និងតូបលក់សៀវភៅនានា
023 216 001
siparedition@online.com.kh



កម្មវិធីវិទ្យុ
អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ ថ្ងៃ សៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតសម្រាប់លេខនេះ


Photos : L. Sovanna

លោកប៊ិន សំណាង ចូលរួមដង្ហែកម្រងផ្កាគោរពវិញ្ញាណក្ខន្ធ នាខួបប្រាំឆ្នាំនៃសពលោកជា វិជ្ជា មេសហជីពសេរីកម្មករកម្ពុជា កាលពីថ្ងៃព្រហស្បតិ៍ទី២២ មករា កន្លងទៅនៅឯរបងវត្តលង្កាក្រុងភ្នំពេញ។ លោកត្រូវបានដោះលែង នៅខណៈវិញ្ញាក្ខន្ធលោកជា វិជ្ជា កំពុងរង់ចាំឱ្យអាជ្ញាធរស្វែងរកយុត្តិធម៌ឱ្យផងដែរ **(ឆ្វេង)**

ពិធីជប់លៀងឆ្លងឆ្នាំសកល កាលពីថ្ងៃទី៤ មករា ធ្វើនៅគេហដ្ឋានលោកអេមីល ដេតម្ប អភិបាលព្រះសហគមន៍កាតូលិកប្រចាំភូមិភាគភ្នំពេញ និងមានលោកបូជាចារ្យ និងគ្រីស្តបរិស័ទចូលរួមយ៉ាងច្រើនកុះករ។ **(ក្រោម)**




Photo : S. Philong

គ្រីស្តបរិស័ទបឹងទំពុនចូលរួមផ្តល់ឈាមកាលពីថ្ងៃទី១៨ មករា។ ទង្វើនេះបង្ហាញទឹកចិត្តសណ្តោសប្រោសប្រណីដែលមកពីព្រះជាម្ចាស់។ **(លើ)**

កម្មវិធីរបស់ព្រះសហគមន៍ព្រៃវែងដែលមានយុវជនដឹកនាំកុមារឱ្យចេះអានដើម្បីលើកស្ទួយវិស័យអំណានសម្រាប់កុមារនៅកម្ពុជាឱ្យបានរីកចម្រើន **(ស្តាំ)**



ការផ្តល់ឈាមគឺជាកិច្ចការសប្បុរសធម៌មួយដែលមានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ជួយដល់ជនរងគ្រោះដោយគ្រោះថ្នាក់ ឬជំងឺផ្សេងៗ។ ចំណែកព្រះសហគមន៍ក៏មានកម្មវិធីផ្តល់ឈាមជាទៀងរាល់បីខែម្តងផងដែរ **(ឆ្វេង)**


Photo : Prey Veng Church



# វិចារណកថា

## វិបត្តិសេដ្ឋកិច្ច ជាបន្ទុកថ្មីរបស់រដ្ឋាភិបាល


Photo : L. Samphors

លោកលី សុវណ្ណា ចាងហ្វាងការផ្សាយអ្នកនាំសារ

ក្នុងរយៈពេលចុងក្រោយនេះ វិបត្តិសេដ្ឋកិច្ចពិភពលោក បានធ្វើឱ្យជីវភាពរបស់ប្រជាជនមានការលំបាកយ៉ាងខ្លាំងប្រឈមនឹងការគ្មានការងារធ្វើ ខ្វះប្រាក់ចំណូល និងទំនិញឡើងថ្លៃជាដើម ជាពិសេសធ្វើឱ្យមានការប៉ះពាល់ដល់ការវិនិយោគនានាក្នុងនោះមានការវិនិយោគលើវិស័យអចលនទ្រព្យផងដែរ។ វិបត្តិសេដ្ឋកិច្ចផ្តើមចេញពីវិបត្តិហិរញ្ញវត្ថុនេះ វាក៏បានប៉ះពាល់យ៉ាងខ្លាំងដល់ប្រទេសកំពុងអភិវឌ្ឍន៍ មានកម្ពុជាជាដើម។ ចំពោះវិស័យអចលនទ្រព្យ វាបានឡើងថ្លៃយ៉ាងកប់ពពកនៅប្រទេសកម្ពុជារហូតដល់ពាក់កណ្តាលឆ្នាំ២០០៨។ សំណង់ផ្ទះល្វែងនានាត្រូវបានសាងសង់ឡើង រីកដូចផ្សិតនៅជុំវិញទីក្រុងភ្នំពេញ និងបណ្តាទីប្រជុំជនធំៗ។ រីឯតម្លៃដីបានឡើងទ្វេដងពីមួយថ្ងៃទៅមួយថ្ងៃ។ ចំនុចនេះក៏បានជួយឱ្យជីវភាពប្រជាជនខ្មែរដែលមានដីលក់ គឺបានធូរធាមួយកម្រិត។ "ដែនដីខ្មែរប្រែថាសុវណ្ណភូមិ" ក្លាយជាការពិតដីថ្លៃជាងមាស។ ស្របពេលជាមួយគ្នានេះវិបត្តិនៃវិវាទដីធ្លីក៏បានកើតឡើងស្ទើរគ្រប់ទិសទី។ ការតវ៉ាចំពោះការរំលោភបំពានបានកើតឡើងជាហូរហែដែរ។

ក្នុងដើមឆ្នាំ២០០៩នេះ ទីផ្សារអចលនទ្រព្យបាននៅទ្រឹងមួយកន្លែង គ្មានទីផ្សារ ដែលធ្វើឱ្យក្រុមហ៊ុនមួយចំនួន ផ្អាកដំណើរការ ឬធ្វើសកម្មភាពដោយយឺតៗ។ ក្រុមហ៊ុនផ្ទះល្វែងខ្លះបានទម្លាក់តម្លៃស្ទើរពាក់កណ្តាលហើយ តែនៅតែគ្មានអតិថិជន។ ចំពោះអ្នកដែលត្រូវការលុយដើម្បីបង្វិលបានទម្លាក់តម្លៃពាក់កណ្តាល ក៏គ្មានអ្នកទិញដដែល។ ក្នុងស្ថានភាពបែបនេះ ធ្វើឱ្យអ្នកវិភាគវាយតម្លៃខុសៗគ្នា។ ទោះបីជាទីផ្សារអចលនទ្រព្យបានធ្លាក់ចុះ ឬគ្មានទីផ្សាក៏ដោយ។ ប៉ុន្តែវិវាទដីធ្លីបានកើត និងកំពុងមានសំទុះយ៉ាងពេញទំហឹងនៅឡើយ។

បញ្ហាប្រឈមទាំងឡាយនេះ មានជម្លោះដីធ្លី ការធ្លាក់ចុះតម្លៃនៃអចលនទ្រព្យ គឺជាបន្ទុកដ៏ធ្ងន់ថ្មីមួយទៀតសម្រាប់រដ្ឋាភិបាលដែលត្រូវតែរកវិធីដោះស្រាយឱ្យបានឆាប់រហ័សផង និងសមស្របផង បើទោះបីជាថា ប្រទេសកម្ពុជានៅពុំទាន់ឈានជើងយ៉ាងជ្រៅទៅក្នុងទីផ្សារសេដ្ឋកិច្ចពិភពលោកក៏ដោយ។

CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org
ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្សឺរ៉ាល់ដូ។
ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា។
Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៩ ថ្មី ដែលជាចម្រៀងពណ៌នាអំពីតង្វាយដែលថ្វាយទៅព្រះជាម្ចាស់។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ បើប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវនោះ សូមទំនាក់ទំនងលេខទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។/

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

**សេវាកម្មជាទីគាប់ចិត្ត !** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទាក់ទងទូរស័ព្ទ : ០១២ ៣៧៧ ៤៦០។/

**សារសម្រាប់មិត្តអ្នកអាន!**



បើប្រិយមិត្តចង់មានមតិយោបល់ទៅលើអត្ថបទ មានចម្ងល់ ឬចង់ផ្តល់មតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាសយដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្តល់នូវការឆ្លើយតបដោយក្តីរីករាយ។

**សូមប្រិយមិត្តមើល និងកំសាន្តជាមួយល្បែងរូបភាព នៅទំព័រទី ១៦ រួចមើលជំនួយគំនិតនេះៗ**

**សេចក្តីជូនដំណឹង !** *"ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកដោយមិនគិតថ្លៃ"* គ្រប់អង្គការក្រុមហ៊ុន និងស្ថាប័នទាំងអស់ដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាបបំផុត ហើយចំណេញបានច្រើន សូមទំនាក់ទំនងមកកាន់ការិយាល័យអ្នកនាំសារ ឬអាចទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។
បញ្ជាក់ : គ្រប់ដំណឹងផ្សព្វផ្សាយជ្រើសរើសបុគ្គលិកទាំងអស់ដែលគ្មាន Logo របស់អង្គការក្រុមហ៊ុន ឬស្ថាប័ននានា យើងខ្ញុំនឹងចុះផ្សាយដោយមិនគិតថ្លៃឡើយ។/

February-2009.qxd 1/24/2009 4:38 PM Page 4

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

**ថ្ងៃអាទិត្យទី ៤ ក្នុងរដូវធម្មតា (ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៩)**

*"លោកបង្រៀនតាមរបៀបថ្មី ប្រកបដោយអំណាច"* ( ម៉ាកូស ១,២១-២៨)

ព្រះយេស៊ូទើបទទួលពិធីជ្រមុជទឹកពីលោកយ៉ូហាន ហើយចាប់ផ្ដើមបំពេញព្រះរាជកិច្ចនៅធម្មសាលាក្រុងកាផានុម ។ ព្រះអង្គសម្ដែងធម្មទេសនា និងរំដោះមនុស្សម្នាក់ឱ្យរួចពីអំណាចរបស់ពួកមារ ។ លោកម៉ាកុបថែងសេចក្ដីនេះ ដោយប្រើនិមិត្តរូបហាក់ដូចជាមារប្រកែកតវ៉ានឹងព្រះយេស៊ូ ។ មារស្គាល់ឋានៈរបស់ព្រះយេស៊ូ "អ្នកដ៏វិសុទ្ធដែលមកពីព្រះជាម្ចាស់" និងមានអំណាចអាចឈ្នះសេចក្ដីអាក្រក់គ្រប់យ៉ាងបាន ។

យើងជាគ្រីស្ដបរិស័ទជឿថា ព្រះយេស៊ូដែលទទួលព្រះជន្មថ្មីដ៏រុងរឿង ហើយព្រះអង្គពោរពេញដោយព្រះវិញ្ញាណជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ។ ព្រះអង្គអាចរំដោះយើងម្នាក់ៗ ឱ្យរួចពីអ្វីដែលបន្ថោកតម្លៃនៃជីវិតយើងជាបុត្រធីតាដ៏វិសុទ្ធរបស់ព្រះបិតា មានតណ្ហាដែលទាក់ទាញចិត្តយើងជាដើម ។ យើងក៏ផ្ញើជីវិតទាំងស្រុងលើព្រះអង្គដែលបានឈ្នះសេចក្ដីអាក្រក់គ្រប់យ៉ាង ។

តើសព្វថ្ងៃ មានអ្វីបណ្ដាលឱ្យជីវិតខ្ញុំអន់ ឬបាត់កិត្តិយស? តើខ្ញុំត្រូវការព្រះយេស៊ូរំដោះខ្ញុំឱ្យរួចពីអ្វីខ្លះ?

**ថ្ងៃអាទិត្យទី ៥ ក្នុងរដូវធម្មតា (ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៩)**

*"ព្រះយេស៊ូយាងទៅគ្រប់ទីកន្លែង ព្រមទាំងដេញខ្មោចចេញពីមនុស្សផង"* ( ម៉ាកូស ១,២៩-៣៩)

ក្រោយពីបានសម្ដែងធម្មទេសនានៅធម្មសាលាក្រុងកាផានុម ព្រះយេស៊ូប្រោសម្ដាយក្មេកលោកស៊ីម៉ូន ។ ព្រះយេស៊ូយាងមកប្រោសឱ្យមនុស្សបានរួចអំពីអំណាចរបស់មារ ជាសេចក្ដីអាក្រក់គ្រប់យ៉ាងដែលយាយីមនុស្ស និងមានជំងឺជានិមិត្តរូប ។ យើងឃើញថា ព្រះអង្គមិននៅមួយអង្គឯងទេ គឺមានសាវ័កបីនាក់ នៅជាមួយអង្គព្រះអង្គប្រោសម្ដាយក្មេកលោកស៊ីម៉ូន ។ បីនាក់នោះជាតំណាងព្រះសហគមន៍ ។ ព្រះអង្គត្រូវការព្រះសហគមន៍គឺត្រូវការយើងរួមសហការក្នុងកិច្ចសង្គ្រោះមនុស្សលោក ។ ម្ដាយក្មេកលោកស៊ីម៉ូនគ្រុននៅលើគ្រែជានិមិត្តរូបអំពីមនុស្សយើងដែលធ្វើអ្វីមិនកើត ។ ព្រះអង្គចាប់ដៃគឺប៉ះគាត់ ដូចព្រះអង្គប៉ះរូបកាយយើងតាមអគ្គសញ្ញានានា ។ ព្រះអង្គប្រោសឱ្យគាត់ "ក្រោកឡើង" គឺឱ្យទទួលជីវិតថ្មីដ៏រុងរឿងរួមជាមួយព្រះអង្គ ។ រួចម្ដាយក្មេកបម្រើភ្ញៀវ គឺបម្រើព្រះសហគមន៍វិញ ។

ព្រះយេស៊ូ និងគ្រីស្ដបរិស័ទអាចប្រោសមនុស្សបានដោយការអធិដ្ឋានរួមយ៉ាងជិតស្និទ្ធជាមួយព្រះបិតា ។

**ថ្ងៃអាទិត្យទី ៦ ក្នុងរដូវធម្មតា (ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៩)**

*"ចូរឱ្យអ្នកបានជាស្អាតបរិសុទ្ធចុះ!"* ( ម៉ាកូស ១,៤០-៤៥)

ព្រះយេស៊ូប្រោសមនុស្សឃ្លង់ ឱ្យបានជាសះស្បើយ ។ ជនជាតិយូដាតែងប្រកាន់ថា មនុស្សឃ្លង់ជា "មនុស្សមិនបរិសុទ្ធ" និងទទួលកម្មពៀរដែលខ្លួនបានប្រព្រឹត្ត ។ គេធ្លាប់ដេញមនុស្សឃ្លង់ឱ្យរស់នៅក្រៅសង្គមរបស់គេ ព្រោះគេយល់ឃើញថា គឺគេជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះដ៏វិសុទ្ធ ។ តែព្រះយេស៊ូអាណិតគេ និងលូកព្រះហស្តមកពាល់គេ ។ ព្រះអង្គហ៊ានរំលោភប្រពៃណីអ្នកស្រុក ហើយត្រឡប់ទៅជាមនុស្ស "មិនបរិសុទ្ធ" ដែលមិនអាចចូលក្រុងគេដូចមនុស្សឯទៀតៗបាន ។ ព្រះអង្គពិតជាផ្ទុកបាបកម្មរបស់មនុស្សលោក ។

យើងជាគ្រីស្ដបរិស័ទ ប្រៀបបីដូចមនុស្សឃ្លង់ដែលព្រះអង្គប្រោសឱ្យចូលក្នុងប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះបិតា ។ ហេតុនេះកុំប្រកាន់នរណាឱ្យសោះ ដោយចោទថា គេជាមនុស្សខូចនិងមានអតីតកាលពុំល្អ ។ យើងមើលមនុស្សម្នាក់ៗ ដោយមានចិត្តអាណិតអាសូរ ដូចព្រះយេស៊ូដែរ ។

**ថ្ងៃអាទិត្យទី ៧ ក្នុងរដូវធម្មតា (ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៩)**

*"ចូរក្រោកឡើង យកគ្រែស្នែងរបស់អ្នក ដើរទៅផ្ទះវិញទៅ!"* ( ម៉ាកូស ២,១-១២)

ព្រះយេស៊ូនៅតែបន្តព្រះរាជកិច្ច គឺក្នុងអត្ថបទអាននៅថ្ងៃនេះ ព្រះអង្គបញ្ជាក់យ៉ាងច្បាស់ថា ព្រះអង្គមានអំណាចប្រោសមនុស្សឱ្យរួចពីបាបបាន ។ មានមនុស្សបួននាក់សែងអ្នកខ្វិនដៃ ខ្វិនជើងម្នាក់ ចោះប្រហោងដំបូលផ្ទះសម្រូតជនពិការនោះមកដាក់នៅមុខព្រះអង្គ ។ ព្រះយេស៊ូមិនប្រោសឱ្យគេជាភ្លាមទេ គឺព្រះអង្គមានព្រះបន្ទូលថា: "ខ្ញុំ ( ឬព្រះជាម្ចាស់) អត់ទោសឱ្យអ្នកបានរួចអំពីបាប" ។ ព្រះអង្គទតឃើញមូលហេតុបណ្ដាលឱ្យមនុស្សទៅជាខ្វិនដៃ ជើង មិនអាចទាក់ទងជាមួយព្រះបិតា និងជាមួយអ្នកដទៃបាន ។

ព្រះយេស៊ូប្រោសយើងឱ្យ "ក្រោកឡើង" ឱ្យមានជីវិតថ្មីដ៏រុងរឿងរួមជាមួយព្រះអង្គ ។ យើងយកគ្រែស្នែងរបស់យើង គឺអតីតកាលរបស់យើង អំពើអាក្រក់ដែលយើងបានប្រព្រឹត្តកន្លងមក ភាពកម្ចិលរបស់យើង ភាពល្ងង់របស់យើងត្រឡប់ទៅផ្ទះ ។ យើងលែងជាប់ចំណងដោយសារអំពើបាប ។ ជីវិតទទួលតម្លៃវិញ ។

*(អ្នកនាំសារ ខែកុម្ភៈ ២០០៩ - អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ / លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍)*

## យើងអាន



Photo: DR

**ជំរាបសួរប្អូនៗ**

ពេលនេះយើងបានឆ្លងនូវរដូវបុណ្យព្រះយេស៊ូប្រសូតរួចហើយ តើប្អូនៗមានអារម្មណ៍យ៉ាងណាដែរ ? តើប្អូនៗចូលរួមជាមួយព្រះកុមារយេស៊ូយ៉ាងណាខ្លះ ?

ក្នុងអ្នកនាំសារកន្លងទៅ យើងបានរិះគិតរួមគ្នាជីវិតរបស់គ្រីស្ដទូតប៉ូល។ លោកគឺជាមនុស្សម្នាក់ដែលប្រឆាំងជាមួយគ្រីស្ដបរិស័ទ។ លោកបានកែប្រែចិត្តគំនិតដោយព្រះយេស៊ូបង្ហាញការអស្ចារ្យឱ្យលោកបានស្គាល់ ពេលលោកធ្វើដំណើរទៅកំចាត់គ្រីស្ដបរិស័ទនៅក្រុងដាម៉ាស។ ក្រោយលោកកែប្រែចិត្តគំនិតលោកបានទទួលអគ្គសញ្ញាជ្រមុជទឹក ហើយចេញប្រកាសដំណឹងល្អពីព្រះយេស៊ូគ្រីស្ដមានព្រះជន្មដ៏រុងរឿង។ លោកបានចេញទៅគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូលនាំឱ្យមនុស្សគ្រប់ជាតិគ្រប់សាសន៍បានទទួលដំណឹងល្អពីការសង្គ្រោះរបស់ព្រះជាម្ចាស់។ ក្នុងការធ្វើដំណើរ គ្រីស្ដទូតប៉ូលជួបការលំបាកជាច្រើនទាំងតាមផ្លូវទឹក និងផ្លូវគោក។ តាមផ្លូវទឹក ជួបនូវខ្យល់ព្យុះបោកបក់ធ្វើឱ្យលិចទូកសំពៅ។ នៅតាមផ្លូវគោកត្រូវគេចាប់ឃុំឃាំងជាញឹកញាប់ និងត្រូវគេបណ្ដេញចេញពីស្រុក។ ទោះបីជាយ៉ាងណា នៅពេលលោកជួបឧបសគ្គ ព្រះជាម្ចាស់គង់នៅជាមួយលោកជានិច្ច។ ព្រោះតែដំណឹងល្អ លោកត្រូវគេកាត់ទោសប្រហារជីវិតដូចព្រះយេស៊ូដែរ គឺ "ត្រូវគេកាត់ក" លោកសុខចិត្តស្លាប់ដើម្បីដំណឹងល្អបានមកដល់យើងទាំងអស់គ្នានៅថ្ងៃនេះ។

រឿងនេះហាក់ធ្វើឱ្យប្អូនៗ មានការភ័យខ្លាចបន្តិច តែគ្រីស្ដប៉ូលជាគំរូដ៏ល្អសម្រាប់យើងជាអ្នកដែលដើរតាមព្រះយេស៊ូ។ ប្អូនៗស្គាល់ព្រះយេស៊ូនៅថ្ងៃនេះ គឺដោយសារលោកប៉ូល រួមនិងគ្រីស្ដទូតឯទៀតៗ។ ដូច្នេះយើងត្រូវរៀនពីគំរូរបស់គ្រីស្ដទូតប៉ូល និងធ្វើជាសាក្សីពីព្រះយេស៊ូដល់បងប្អូនឯទៀតដែលមិនទាន់ស្គាល់ព្រះអង្គ។ តើខ្ញុំអាចធ្វើអ្វីខ្លះដើម្បីឱ្យបងប្អូនផ្សេងទៀតបានស្គាល់ព្រះយេស៊ូតាមរយៈខ្ញុំ ? តើមិត្តភក្តិទាំងឡាយធ្លាប់មិននិយាយរកខ្ញុំ ពីព្រោះតែខ្ញុំជាគ្រីស្ដបរិស័ទដែរឬទេ ?

លី សុវណ្ណា



# ព័ត៌មានទូទៅ

## អ្នកដាក់គ្រាប់បែក ៤នាក់ ត្រូវចោទប្រកាន់ពីបទភេរវកម្ម

ជនសង្ស័យ ៤នាក់ ដែលពាក់ព័ន្ធនឹងការបង្កៃគ្រាប់បែកកាលពីថ្ងៃទី២ មករា នៅក្បែរក្រសួងការពារជាតិ និងស្ថានីយទូរទស្សន៍ប៉ុស្តិ៍លេខ៣ ត្រូវតុលាការក្រុងភ្នំពេញធ្វើការចោទប្រកាន់កាលពីថ្ងៃទី១២ ខែមករា ពីបទ "កេណ្ឌភេរវករ និងដាក់គ្រាប់បែកផ្ទុះនៅតាមផ្លូវសាធារណៈ" ។ នៅក្នុងសន្និសីទសារព័ត៌មានមួយកាលពីថ្ងៃទី១០ ខែមករា នគរបាលក្រសួងមហាផ្ទៃ បានបង្ហាញភ័ស្តុតាងដែលប្រមូលបានក្រោយពេលចាប់ខ្លួន ។ ក្រុមនេះមានចលនារបៀបចោរព្រៃ ហើយដាក់ឈ្មោះខ្លួនថា "រណសិរ្សរំដោះជាតិខ្មែរ" ព្រមទាំងបានបង្ហាញអត្តសញ្ញាណមេខ្លោងម្នាក់ដែលជាអតីតសមាជិក "កងទ័ពសេរីជាតិកម្ពុជា (CFF) " ។

## គណបក្សប្រជាជនកម្ពុជាប្រារព្ធខួប ៣០ឆ្នាំ នៃ ថ្ងៃ ៧ មករា

គណបក្សប្រជាជនកម្ពុជាបានប្រារព្ធខួបទី៣០ឆ្នាំ នៃថ្ងៃ ៧ មករា ( ៧ មករា ១៩៧៩- ៧ មករា ២០០៩) ដ៏ធំជាលើដំបូងនៅឆ្នាំនេះ ដែលមានមនុស្សប្រមាណជាង ៨ម៉ឺននាក់ មកពីទូទាំងប្រទេសត្រូវបានគេអញ្ជើញឱ្យចូលរួមនៅក្នុងពិធីនេះ នៅពហុកីឡាដ្ឋានជាតិអូឡាំពិក ។ សម្ដេចជា ស៊ីម ជាប្រធានគណបក្ស មានប្រសាសន៍ថា ការប្រារព្ធខួបទី ៣០ឆ្នាំ នៃថ្ងៃ៧ មករា នៅថ្ងៃនេះ គឺក្នុងគោលបំណងរំឭកដល់វិញ្ញាណក្ខន្ធកងទ័ពកម្ពុជាទាំងឡាយ ដែលបានពលីជីវិតក្នុងបុព្វហេតុរំដោះជាតិមាតុភូមិពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នាថ្ងៃ៧ មករា ១៩៧៩ ។ សម្ដេចក៏បានថ្លែងអំណរគុណដល់ក្រុមគ្រួសារយុទ្ធជនវៀតណាម ដែលបានលះបង់កូនចៅប្ដីសីដើម្បីបុព្វហេតុអន្តរជាតិ ។ ក្រៅពីនេះ លោកក៏បានលើកសរសើរពីសមិទ្ធផល និងការរីកចម្រើននានាដែលគណបក្សដឹកនាំប្រទេសបានធ្វើរយៈពេល ៣០ឆ្នាំ កន្លងមកនេះ ។



Photo: P. Samphy

## សម្ដេចហ៊ុន សែន : "សម្ដេចក្រុមព្រះស្មើឋានៈ តែមិនស្មើអំណាចទេ"

ដើម្បីបញ្ចៀសនូវការភាន់ច្រឡំនានារបស់ប្រជាពលរដ្ឋពីតួនាទីរបស់សម្ដេចក្រុមព្រះនរោត្ដម រណឫទ្ធិ ដែលត្រូវបានព្រះមហាក្សត្រតែងតាំងជាប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ កាលពីខែធ្នូ មានឋានៈស្មើនាយករដ្ឋមន្ត្រី ។ សម្ដេចហ៊ុន សែន បានបញ្ជប់មន្ទិលនេះថា ឋានៈថ្មីរបស់ព្រះអង្គម្ចាស់នរោត្ដម រណឫទ្ធិ គឺសម្រាប់បើកប្រាក់ខែប៉ុណ្ណោះ ។ នាឱកាសសម្ពោធដាក់ឱ្យប្រើប្រាស់ស្ពានស្ទឹងមានជ័យថ្មី នៅថ្ងៃទី៦ ខែមករា ប្រមុខរាជរដ្ឋាភិបាល បានបញ្ជាក់ថា ឋានៈថ្មីរបស់សម្ដេចក្រុមព្រះ ក្រៅតែពីប្រាក់ខែ គឺគ្មានអ្វីទាំងអស់ ដូចជាអ្នកនាំពាក្យ ជំនួយការ ឆ្វេងស្ដាំ ទីប្រឹក្សា រួមទាំងឡានស៊ីរ៉ែនផ្ទាល់ខ្លួន ។ សម្ដេចក៏បានបង្ហើបឱ្យដឹងថា មានមនុស្សមួយចំនួនកំពុង រត់ការជ្រើសរើសមនុស្សធ្វើការក្រោយខ្នងសម្ដេចក្រុមព្រះដែលមានទាំងអ្នកនាំពាក្យ និងមន្ត្រីខុទ្ទកាល័យទៀតផងដែរ ។

រស់ ឌីណា

## កងទ័ពអ៊ីស្រាអែលវាយលុកចូលតំបន់ហ្គាហ្សា



Photo : DR

កងទ័ពអ៊ីស្រាអែល អមដោយរថក្រោះ និងកាំភ្លើងធំ បានធ្វើការវាយប្រហារ និងសម្រុកចូល ទៅកាន់តំបន់ហ្គាហ្សា ដែលជាដែនដីរបស់ប៉ាលេស្ទីន កាលពីព្រឹកព្រលឹមថ្ងៃទី១៥ ខែមករា កន្លងទៅ បើទោះបីជាមានកិច្ចប្រឹងប្រែងពីសហគមន៍អន្តរជាតិឱ្យមានបទឈប់បាញ់គ្នាមួយក្ដី ។ រ៉យទ័របានឱ្យដឹងថា នៅមុនការលុកលុយរបស់កងទ័ពអ៊ីស្រាអែលចូលទៅក្នុងតំបន់ហ្គាស្សា អ៊ីស្រាអែលបានធ្វើការវាយប្រហារទៅលើតំបន់នេះ តាំងតែពីចុងខែធ្នូ ឆ្នាំ២០០៨ មកម្ល៉េះ ។ អ៊ីស្រាអែល ក៏អះអាងថា កងជីវពលរបស់ចលនាហាម៉ាសបានបើកការបាញ់ប្រហារដោយគ្រាប់រ៉ូកែតសម្លាប់ជនស៊ីវិលរបស់ខ្លួនដែរ ។

កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩ ពួកហាម៉ាសអះអាងថា ការវាយប្រហាររបស់អ៊ីស្រាអែល បានសម្លាប់ជីវិតមនុស្សយ៉ាងហោចណាស់ ក៏ ១០២៤នាក់ដែរ ។ ចំណែកក្រុមប៉ាលេស្ទីនស្របច្បាប់វិញបញ្ជាក់ថា ជនស៊ីវិល មានស្លាប់ប្រមាណ៦៧០នាក់ តែប៉ុណ្ណោះ ។

ហ្គាហ្សាជាតំបន់របស់ជនជាតិប៉ាលេស្ទីនរស់នៅ ចំណែកពួកហាម៉ាសគឺជាក្រុមកងជីវពលក្រៅច្បាប់តស៊ូដើម្បីឯករាជ្យភាពនៃប៉ាលេស្ទីន ។

## ឧប្បត្តិហេតុលិចសាឡាងនៅប្រទេសឥណ្ឌូនេស៊ី ស្លាប់មនុស្ស ១០៣នាក់

សារព័ត៌មានរ៉យទ័រ បានឱ្យដឹងថា ឧប្បត្តិហេតុលិចសាឡាងមួយនៅប្រទេសឥណ្ឌូនេស៊ី បានសម្លាប់ជីវិតមនុស្សយ៉ាងហោចណាស់ក៏១០៣នាក់ដែរ ។ នៅលើសាឡាងនេះ មានផ្ទុកមនុស្សដល់ទៅ ២៥០នាក់ និងនាវិកចំនួន ១៧នាក់ ។ តែអ្នកនាំពាក្យក្រសួងដឹកជញ្ជូនរបស់រដ្ឋាភិបាលឥណ្ឌូនេស៊ី អះអាងថា ជនរងគ្រោះ គឺមានត្រឹមតែ ១០៣នាក់ តែប៉ុណ្ណោះ ។

ឧបត្តិហេតុនេះ បានកើតមានឡើងកាលពីថ្ងៃទី១១ ខែមករា ឆ្នាំ ២០០៩ ។ មន្ត្រីឥណ្ឌូនេស៊ីបញ្ជាក់ថា គេកំពុងតែស្វះស្វែងរកព័ត៌មានពិតអំពីឧប្បត្តិហេតុ និងចំនួនពិតប្រាកដនៃជនរងគ្រោះ ។ ការសន្និដ្ឋានជំហានដំបូងឧប្បត្តិហេតុនេះ កើតមានឡើង ដោយសារតែអាកាសធាតុ ។ ប្រតិបត្តិការរុករកអ្នកនៅមានជីវិត និងសាកសពបានដំណើរការ ប៉ុន្តែគេនៅពុំទាន់អាចរកឃើញអ្វីទាំងអស់ក្រៅអំពីតួលេខខាងលើ ដោយសារឧបសគ្គនៃអាកាសធាតុដែលធ្វើឱ្យកម្ពស់រលកទឹកសមុទ្រមានពី៤ម ទៅ ៦ម ។

ខាន់ ភិរម្យ

February-2009.qxd 1/24/2009 4:38 PM Page 6



# ប្រជាជនចូលរួមបុណ្យព្រះយេស៊ូប្រសូតយ៉ាងច្រើនកុះករ

**ជាត សំភី**

កាលពីថ្ងៃទី២៤ ខែធ្នូ នៅព្រះសហគមន៍កាតូលិកចំការទៀង នៅឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ មានរៀបចំពិធីអំណរបុណ្យព្រះយេស៊ូប្រសូត និងដឹកនាំដោយលោកបូជាចារ្យអូលីវីយេ ប្រកបដោយភាពអធិកអធមយ៉ាងក្រៃលែង ដែលមានការចូលរួមពីគ្រីស្តបរិស័ទ និង ប្រជាជនប្រមាណពី ២០០០ ទៅ៣០០០នាក់ នៅក្នុងភូមិ និងតំបន់ជិតនោះ។

លោកបូជាចារ្យអូលីវីយេ ជាអ្នកទទួលខុសត្រូវនៅព្រះសហគមន៍កាតូលិកចំការទៀង មានប្រសាសន៍ថា ការរៀបចំនូវកម្មវិធីបុណ្យព្រះយេស៊ូប្រសូតឆ្នាំនេះគឺដើម្បីផ្តល់សេចក្តីសុខ ឱ្យប្រជាជនទាំងអស់។ សម្រាប់គ្រិស្តបរិស័ទ និងពុទ្ធបរិស័ទរួមជាមួយគ្នា នេះបង្ហាញថា នេះជារបៀបមួយដែលយើងបង្កើតពិភពលោកថ្មី ដែលទាំងអស់គ្នា មានការយល់ចិត្តគ្នា និងគោរពគ្នាទៅវិញទៅមក។

សម្រាប់បុណ្យណូអែលឆ្នាំនេះ ព្រះសហគមន៍ចំការទៀង ក៏មានរៀបចំពិធីអភិបូជា និងកម្មវិធីសិល្បៈ ដូចជាការសម្តែងល្ខោនរឿងព្រះយេស៊ូប្រសូត របាំជូនពរ រឿងរាមកេរ្តិ៍ រឿងកំប្លែង កំសត់ និងមានការប្រគុំតន្ត្រីសម័យពីក្រុមសិល្បៈមកពីស្រុកដូនតី ខេត្តតាកែវ។ លើសពីនេះ ក៏មានកម្មវិធីចាប់ឆ្នោតដើម្បីរកថវិកាជួយសង់ផ្ទះជូនអ្នកក្រីក្រផងដែរ។



Photo : P. Samphy

ប្រជាជនយ៉ាងច្រើនកុះករមកចូលរួមអំណរ នឹងថ្ងៃបុណ្យព្រះយេស៊ូប្រសូត ដែលបង្ហាញអំពីសាមគ្គីភាពរវាងគ្រីស្តបរិស័ទ និងពុទ្ធបរិស័ទ

## បាចទឹកព្រះពរដល់ផ្ទះថ្មី



Photo : L. Sovanna

ផ្ទះថ្មីមួយខ្នងមានកម្ពស់៣ជាន់ ជាអំណោយរបស់សប្បុរសជនបារាំង ជូនដល់គ្រួសារពន្លឺមិត្តភាព ដែលស្ថិតនៅសង្កាត់ ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ និងត្រូវបានទទួលពិធីបាចទឹកព្រះពរ ដោយមានការចូលរួមជាអធិបតីភាពពីលោកអភិបាលភូមិភាគភ្នំពេញអេមីល ដេតម្ប ភ្ញៀវជាតិ និងអន្តរជាតិប្រមាណជាជាង ២០នាក់ កាលពីថ្ងៃទី៦ ខែមករាកន្លងទៅនេះ។

លោកអភិបាលមានប្រសាសន៍ថា: "ការងាររបស់គ្រួសារពន្លឺមិត្តភាព ជាសកម្មភាពមួយដែលធ្វើការយ៉ាងខ្លាំងទៅលើការគោរពសិទ្ធិមនុស្សគ្រប់គ្នា ពិសេសតម្លៃកម្មការិនីរោងចក្រកាត់ដេរ។ នេះគឺជាអ្វីមួយសំខាន់ ដែលយើងត្រូវប្រាប់ថា ជីវិតពួកគេមានតម្លៃទោះបីពួកគេមិនបានរិះគិតអំពីសេដ្ឋកិច្ច និងផលត្រឡប់របស់វាមកវិញយ៉ាងណាក៏ដោយ"។

**កែវ កញ្ញា**

## ក្រុមគ្រូពេទ្យស្ម័គ្រចិត្តកូរ៉េជួយព្យាបាលអ្នកក្រីក្រ

ក្រុមគ្រូពេទ្យស្ម័គ្រ១ក្រុមពីព្រះសហគមន៍ភូមិភាគសេអ៊ូលប្រទេសកូរ៉េតាមរយៈព្រះសហគមន៍កាតូលិកបាត់ដំបងបានចុះមកជួយព្យាបាល និងពិនិត្យជំងឺដល់ប្រជាជន តាមភូមិនានាក្នុងខេត្តបាត់ដំបង និងបន្ទាយមានជ័យពីថ្ងៃទី១០ ដល់១៤ មករា។

ដូនជីម៉ារី ហ្សង់ណេ អាត អ្នកជួយសម្របសម្រួលក្នុងកម្មវិធីនេះមានប្រសាសន៍ថាក្រុមគ្រូពេទ្យទាំងនេះ បានចំណាយពេលវេលាឈប់សម្រាករបស់ខ្លួនមកជួយពិនិត្យជំងឺ និងផ្តល់ថ្នាំជូនប្រជាជខ្មែរ។បងស្រីបន្តថា រយៈពេល ៥ថ្ងៃ គ្រូពេទ្យកូរ៉េបានពិនិត្យជំងឺត្រចៀក ធ្មេញ និងជំងឺទូទៅជូនប្រជាជន ចំនួនជាង ១៤០០ នាក់ នៅកន្លែងមួយចំនួន ដូចជា ភូមិខ្នាចរមាស តាពូង ខេត្តបាត់ដំបង និងភូមិចំណោម ខេត្តបន្ទាយមានជ័យ។

**វណ្ណា**



Photo : L. Sovanna

## យុវជនបារាំងមកជួយកសាងផ្ទះដល់អ្នកក្រីក្រខ្មែរ

**យុវជនក្រុមគូដីពួសនៃប្រទេសបារាំងចំនួន ១២នាក់ បានមកប្រទេសកម្ពុជា ដើម្បីកសាងផ្ទះជូនដល់អ្នកក្រីក្រ ចំនួន ៣ខ្នង គឺនៅភូមិក្តុលលើ ខេត្តកំពង់ចាម ចំនួនមួយខ្នង និងនៅខេត្តក្រចេះចំនួន ២ខ្នង ដែលការសាងសង់នេះចាប់ផ្តើមពីពាក់កណ្តាលខែមករានេះរហូតដល់ចុងខែ។**

**លោកបូជាចារ្យអ៊ីវ៉ាន់ កំប៉ាញ៉ា អ្នកទទួលខុសត្រូវព្រះសហគមន៍តំបន់ទាំងពីរនេះមានប្រសាសន៍ថា ក្រុមគូដីពួសនេះជាក្រុមយុវជនបារាំង។ រៀងរាល់ឆ្នាំ ពួកគេជ្រើសរើសប្រទេសមួយដើម្បីជួយកសាងផ្ទះដល់អ្នកក្រីក្រ។ ថវិកាដែលពួកគេប្រើបានមកពីការរៃអង្គាសប្រាក់របស់សមាជិកនៅក្រុមក្នុងមួយថ្ងៃ ១០អឺរ៉ូ។ កាលពីឆ្នាំ២០០៨ ក្រុមនេះបានមកជួយជួសជុលផ្ទះ និងសាងសង់ផ្ទះដល់បងប្អូនខ្មែរនៅកំពង់ចាមបានចំនួន៣ខ្នងដែរ។**

**កញ្ញា**



Photo : H. Sokhteary



ព័ត៌មានព្រះសហគមន៍កាតូលិក

# លី ហ៊ាន : "ជួយសង្គម និងអ្នកក្រីក្រ ជាបំណងខ្ញុំ"

**លី សុវណ្ណា**

ដីភូមិដែលមានទំហំ ៣០ម៉ែត្រ គុណ២០ម៉ែត្រ និងផ្ទះឈើចាក់បេតុង ពីខាងក្រោមមួយខ្នង ត្រូវបានប្រគល់ជូនព្រះសហគមន៍កាតូលិក ប្រចាំនៅឯខេត្តបាត់ដំបងដោយស្ត្រីវ័យចំណាស់ម្នាក់ ដើម្បីអាចឱ្យព្រះសហគមន៍យកទៅប្រើប្រាស់ជាប្រយោជន៍ក្នុងការបម្រើសង្គម និងអ្នកជំងឺទីទាល់ក្រ។

លោកយាយលី ហ៊ាន អាយុ ៨៤ឆ្នាំ បានប្រគល់នូវអចលនទ្រព្យរបស់ខ្លួន ដែលបានខិតខំតស៊ូស្វែងរកស្ទើរពេញមួយជីវិត នៅភូមិឈើទាល ឃុំឈើទាល ខេត្តបាត់ដំបងដល់ព្រះសហគមន៍កាតូលិក។

លោកយាយមានប្រសាសន៍ដោយសម្លេងញ័រៗនៅលើរទេះរុញថា ការម្រេចចិត្តប្រគល់ទ្រព្យសម្បត្តិទាំងប៉ុន្មាននេះឱ្យទៅព្រះសហគមន៍ក្នុងបំណងតែមួយ គឺជួយសង្គមនិងមនុស្សដែលត្រូវការសង្គ្រោះពីព្រះសហគមន៍។ នេះគឺជាប្រាថ្នាចុងក្រោយរបស់ជីវិតលោកយាយ។

សម្រាប់អចលនទ្រព្យសម្បត្តិសព្វថ្ងៃនេះ ព្រះសហគមន៍កាតូលិក បានយកមកធ្វើ ជាមណ្ឌលព្យាបាលអ្នកជំងឺសរសៃ និងអ្នកជំងឺស្លាប់មួយចំហៀងខ្លួន។ ដូនជីចាន់ ធូ អ្នកទទួលខុសត្រូវមណ្ឌលព្យាបាលថ្មីនេះ បានឱ្យដឹងថា ព្រះសហគមន៍បានធ្វើការជួសជុលផ្ទះឈើរបស់លោកយាយលី ហ៊ាន នេះ ហើយ និងបើកទទួលឱ្យអ្នកជំងឺសរសៃ ព្រមទាំងអ្នកជំងឺស្លាប់មួយចំហៀងខ្លួនឱ្យចូលព្យាបាលដោយមិនបង់ប្រាក់ចាប់ពីថ្ងៃទី១ មករាមកម្ល៉េះ។ ដូនជីរូបនេះក៏បន្តថា ការព្យាបាលក្នុងមណ្ឌលនេះ គឺដោយការធ្វើចលនាសរសៃ និងការចាក់ម្ជុលវិទ្យាសាស្ត្រ។ ក្នុងមួយថ្ងៃៗមណ្ឌលបើកទទួលអ្នកជំងឺពី៧ ទៅ៨នាក់ ដែលមកពីភូមិនានាក្នុងឃុំឈើទាល។

លោកយាយលី ហ៊ាន ដែលបានមើលឃើញសកម្មភាព និងលទ្ធផលចេញពីការខិតខំរបស់ខ្លួនជិតមួយជីវិតមកនេះ មានប្រយោជន៍ សម្រាប់មនុស្សទាំងអស់ ជាពិសេសអ្នកក្រីក្រដូច្នេះ លោកយាយមានប្រសាសន៍ដោយក្តីរំភើបយ៉ាងនេះថា នៅពេលព្រះសហគមន៍កាតូលិកបានប្រើប្រាស់ផ្ទះរបស់លោកយាយធ្វើជាកន្លែងព្យាបាលអ្នកជំងឺសរសៃ និងអ្នកជំងឺស្លាប់មួយចំហៀងខ្លួនយ៉ាងដូច្នេះ លោកយាយមានអារម្មណ៍សប្បាយរីករាយណាស់។

ចំណែកលោកស្រីសំណាងដែលជាក្មួយ និងជាអ្នកថែរក្សាលោកយាយលី ហ៊ាន ក្នុងវ័យជរា ក៏សម្តែងអារម្មណ៍ត្រេកអរថា លោកស្រីជាក្មួយស្រី ត្រូវតែបំពេញបំណងចុងក្រោយរបស់លោកយាយ។ នេះជាបំណងរបស់លោកស្រី គឺជួយសង្គម និងអ្នកក្រីក្រ។ យើងត្រូវតែមានចិត្ត ដូចជាព្រះជាម្ចាស់ដែលមានព្រះហប្ញទ័យមេត្តាករុណាយ៉ាងនោះដែរ។

លោកបូជាចារ្យតូតែត ជាតំណាងពេញសិទ្ធិ របស់លោកគីកេ ហ្វិការេដូ អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង ក៏មានប្រសាសន៍ថា បងប្អូននៅក្នុងព្រះវិហារព្រះនាងម៉ារីឡើងស្ថានបរមសុខ (ពេទ្យយាយជី) សូមទទួលស្គាល់នូវទឹកចិត្តយ៉ាងសប្បុរសរបស់លោកយាយលី ហ៊ាន ដែលបានលះបង់ទ្រព្យសម្បត្តិដែលបានខិតខំស្វែងរក ហើយសន្សំទុកជិតមួយជីវិតរបស់ខ្លួនសម្រាប់ព្រះសហគមន៍ ដើម្បីឱ្យព្រះសហគមន៍មានសិទ្ធិយកមកប្រើក្នុងផ្លូវមនុស្សធម៌ ជួយបងប្អូនឯទៀតៗ ជាពិសេសអ្នកក្រីក្រ។



លោកយាយ
ដ៏សប្បុរស
លី ហ៊ាង
អង្គុយនៅលើរទេះរុញ

Photo : Etienne

February-2009.qxd 1/24/2009 4:38 PM Page 8



# សមាគមសិប្បកម្មជម្នះភាពទុក្ខលំបាករបស់ជនពិការ

**ជាត សំភី**

ជាមួយនឹងការរីកចម្រើនរបស់សង្គមដូចសព្វថ្ងៃ ជនពិការក៏ត្រូវបានទទួលការយកចិត្តទុកដាក់ផងដែរពីសំណាក់ រាជរដ្ឋាភិបាល អង្គការសប្បុរសធម៌ ឬសមាគមននានា-ល- ក្នុងការទទួលការអប់រំវិជ្ជាជីវៈដើម្បីអាចមានលទ្ធភាពចូលរួមចំណែកកសាងសេដ្ឋកិច្ចជាតិឡើងវិញ។


គេជាជនពិការ តែខិតខំរៀនជំនាញ

Photos : P. Samphy

ជាក់ស្ដែង នៅពេលសព្វថ្ងៃនេះ សមាគមសិប្បកម្មកម្ពុជាសម្រាប់ជនពិការដោយគ្រាប់មីននិងប៉ូលីយ៉ូ ដែលមានលោកហៃ គីមថា ជានាយក បានពុះពារជាខ្លាំងក្នុងការបង្រៀនវិជ្ជាជីវៈ កាត់ដេរ តម្បាញ និងការធ្វើវត្ថុអនុស្សាវរីយ៍ផ្សេងៗ អំពីសូត្រ មានកាតប៉ូស្ដាល់ កាបូប ឬរូបកូនសត្វជាដើមដល់សិស្សពិការអវយវៈ ដែលភាគច្រើនជាស្ត្រី។

លោកហៃ គីមថា មានប្រសាសន៍ឱ្យដឹងថា សមាគមសិប្បកម្មកម្ពុជា បានចាប់បង្កើតឡើងចាប់តាំងពីឆ្នាំ២០០០ដោយរូបលោកផ្ទាល់និងរស់រានដោយសារការលក់ផលិតផលដែលធ្វើបាន។ សព្វថ្ងៃនេះ សមាគម មានទីតាំង ២កន្លែង ទីមួយ នៅរាជធានីភ្នំពេញ និងទីពីរនៅខេត្តសៀមរាប។ ចំណែកគ្រូ គឺម្នាក់មកពីខាងសង្គមកិច្ច និងគ្រូផ្សេងៗទៀត គឺជាជម្រើសសិស្សឆ្នើមដែលបានរៀនរួចហើយ។សិស្សដែលសិក្សានៅទីតាំងភ្នំពេញមាន ១០នាក់ និងនៅសៀមរាបមាន២៤នាក់។ តែចាប់តាំងពីការកកើតរហូតមកដល់បច្ចុប្បន្ន សមាគមបានបណ្ដុះបណ្ដាលសិស្សដែលមានសមត្ថភាពចំនួន២០០នាក់ហើយ។ អ្នកទាំងនោះអាចចេញទៅរកស៊ីខ្លួនឯង ឬមួយទៅធ្វើការនៅតាមអង្គការផ្សេងៗ និងទទួលបានប្រាក់ខែច្រើន។ ខ្លះទៀតមានគ្រួសារទៅខាងក្រៅ។

លោកហៃ គីមថា និយាយបន្ថែមថា សមាគមមិនត្រឹមតែផ្ដល់ជំនាញដល់សិស្សទេ។ សមាគមក៏មានបង្រៀនអំពីសីលធម៌រស់នៅ អំពីសាមគ្គីភាព និងបង្រៀនឱ្យយល់អំពីការតស៊ូក្នុងជីវិត ពោលគឺទោះបីខ្លួនជាជនពិការ ក៏ត្រូវមានក្ដីសង្ឃឹម និងជឿជាក់លើខ្លួនឯងដែរ។ លោកហៃ គីមថា សង្កត់ធ្ងន់ថា៖ "យើងបង្រៀនអ្នកទាំងនោះឱ្យចេះស្ទូចត្រី ពុំមែនឱ្យត្រីហូបទេ។ គោលដៅរបស់យើងគឺឱ្យជនពិការអាចចូលរស់នៅក្នុងសង្គមដូចគេដូចឯងវិញ"។

សូមបញ្ជាក់ដែរថា លក្ខខណ្ឌជ្រើសរើសសិស្សចូលសមាគម គឺទាល់តែអ្នកនោះពិការ ហើយនិងក្រីក្រទៀត។ សមាគមមិនគិតពីកម្រិតវប្បធម៌ទេ។

## លោកហៃ គីមថា : "ការបង្កើតសមាគមផ្ដើមចេញពីចរិតតាំងពីក្មេង"

ក្នុងសម្លៀកបំពាក់សាមញ្ញ លោកមានចរិត ជាអ្នកដឹកនាំម្នាក់។ បុរសវ័យ ៥០ឆ្នាំ មានគ្រួសារ និងកូនបីនាក់រូបនេះ បានមានប្រសាសន៍ថា៖ "ការបង្កើតសមាគមជនពិការផ្ដើមចេញពីចរិតតាំងពីក្មេង" មក មិនមែនទើបតែឥឡូវនេះទេ"។

លោកហៃ គីមថា ក៏បានរៀបរាប់ថា តាំងតែពីក្មេង លោកតែងតែជួយមិត្តភ័ក្តិ ឱ្យតែអ្នកណាក្រ គឺជួយហើយ ព្រោះលោកកើតមកជាកូនអ្នកក្រ គឺដឹងទុក្ខលំបាក។ ជួនកាលថ្ងៃខ្លះពុំមានបាយហូបទេ គឺមានតែបបរហូប។ ដូច្នេះលោកក៏មានគំនិតត្រូវតែជួយខ្មែរអ្នកក្រ ជាពិសេសគឺជនពិការ។

ដោយមានសញ្ញាបត្រជំនាញភាសាអង់គ្លេសតាំងពីឆ្នាំ១៩៧៤មក លោកហៃ គីមថា ក៏មានសមត្ថភាពបានចូលបម្រើការងារ នៅអង្គការមនុស្សធម៌មួយតាំងពីឆ្នាំ១៩៩១។ នោះជាពេលវេលាដែលលោកបានក្រេបជញ្ជក់នូវសមត្ថភាពភាព ជាអ្នកដឹកនាំ។ លោកបានទៅសិក្សានៅប្រទេសឥណ្ឌាអំពីរបៀបរៀបចំគម្រោងបង្កើតអង្គការ។ លោកបានសរសេរគម្រោងបើកជាសមាគមជួយជនពិការ និងក្រីក្រ។



លោកហៃ គីមថា ក៏មានប្រសាសន៍ថា ក្នុងអង្គការមនុស្សធម៌ និងជួបជាមួយភ្ញៀវបរទេសច្រើន ក៏ធ្វើឱ្យលោកទទួលបទពិសោធន៍ គ្រប់បែបយ៉ាង ទាំងការគ្រប់គ្រង ការដឹកនាំ ការស្រាវជ្រាវ និងអនុវត្តការងារ។ លើសពីនេះ អង្គការបានបញ្ជូន លោកឱ្យទៅរៀនជំនាញការគ្រប់គ្រងបុគ្គលិកទៀតផង។

ជាមួយនឹងចំណេះជំនាញ និងបទពិសោធន៍ លោកអាចបើកជាសមាគមសិប្បកម្មកម្ពុជាសម្រាប់ជនពិការដោយសារគ្រាប់មីន និងប៉ូលីយ៉ូ បន្ទាប់ពីបានសុំច្បាប់ពីក្រសួងមហាផ្ទៃ។ លោកក៏និយាយដោយសង្ឃឹមថា៖ "ថ្ងៃអនាគត ខ្ញុំចង់ពង្រីកសមាគមខ្ញុំឱ្យដល់គ្រប់ខេត្តក្រុងដែលមានតំបន់ទេសចរណ៍"។






ពាក់មួកសុវត្ថិភាពដើម្បីការពារជីវិតដ៏មានតម្លៃរបស់អ្នក

Photo : L. Samphors

# តើយុវជនសព្វថ្ងៃ ចង់ពាក់មួកសុវត្ថិភាព ?

**ខាន់ ភីរម្យ និងតន**

យុវជនកម្ពុជាយល់ស្របនឹងច្បាប់ចរាចរណ៍ ដែលកំណត់ឱ្យគ្រប់អ្នកប្រើប្រាស់ទោចក្រយានយន្តជាមធ្យោបាយធ្វើដំណើរពាក់មួកសុវត្ថិភាព។

កញ្ញាស៊ីថន និស្សិតអក្សរសាស្ត្រអង់គ្លេសនៅសកលវិទ្យាល័យបញ្ញាសាស្ត្របាននិយាយថា ការពាក់មួកសុវត្ថិភាព គឺជាការការពារសុវត្ថិភាពរបស់ខ្លួន នៅក្នុងពេលបើកបរ ហើយនិងការពារសម្រស់ប្រឆាំងនឹងកំដៅព្រះអាទិត្យ និងធូលីបាន។ កញ្ញាបញ្ជាក់ថា៖ "មួកជួយបានច្រើនទាំងក្បាល និងសម្រស់"។ កញ្ញាស៊ីថន អះអាងថា គិតមកដល់ពេលនេះកញ្ញាបានប្រើប្រាស់មួកសុវត្ថិភាពក្នុងពេលបើកបរនេះរយៈពេល ៣ឆ្នាំហើយ។ ការដែលកញ្ញាពាក់ យ៉ាងដូច្នេះដោយសារតែវាមានភាពងាយស្រួលសម្រាប់ការបើកបរ ជាពិសេសនៅពេលខ្យល់ ភ្លៀង ហុយដី និងក្ដៅខ្លាំង។ កញ្ញាបន្តទៀតថា ផ្លូវនៅក្នុងក្រុងមួយចំនួន សម្បូរធូលី ហើយនៅពេលថ្ងៃទៀត វាមានកម្ដៅក្ដៅខ្លាំង ដែលធ្វើឱ្យមុខកើតមុនបាន។

ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ គឺជាថ្ងៃដែលប៉ូលីសចរាចរណ៍ផ្លូវគោកកម្ពុជា បានកំណត់ឱសានវាទចុងក្រោយ ឱ្យប្រជាពលរដ្ឋកម្ពុជាទូទៅទាំងអស់ នៅក្នុងប្រទេសដែលប្រើប្រាស់ទោចក្រយានយន្ត ត្រូវពាក់មួកសុវត្ថិភាព។ ចំពោះអ្នកដែលមិនពាក់នឹងត្រូវប្រឈមមុខនឹងការផាកពិន័យតាមដងផ្លូវ។

ពាក់ព័ន្ធជាមួយបញ្ហានេះ កញ្ញាស៊ីថន បានស្វាគមន៍ទាំងស្រុងចំពោះរឿងដែលច្បាប់បានតម្រូវឱ្យពាក់មួក ដើម្បីធ្វើយ៉ាងណាឱ្យមានសុវត្ថិភាព ទាំងអស់គ្នានៅក្នុងពេលបើកបរ បើទោះបីជាកញ្ញាអះអាងថា នៅពេលប្រើមួកដំបូង វាអាចជួប បញ្ហាខ្លះៗ ក៏ដោយ។ កញ្ញាបញ្ជាក់ថា៖ "ពេលពាក់ដំបូង ខ្ញុំគិតថាធ្ងន់ក្បាល ហើយមិនអាចលេងម៉ូតសក់ទៀត តែដល់ពាក់យូរទៅស្រួល គ្រាន់តែខូចរបៀបរៀបរយសក់ តែវាក៏ឱ្យផ្ទៃមុខស្អាត និងមិនប្រឡាក់ដី"។

លោកមាស ពៅរតនៈ និស្សិតផ្នែកច្បាប់នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលទើបតែពាក់មួកពេលច្បាប់តម្រូវឱ្យពាក់នោះ ក៏ទទួលស្គាល់អំពីលក្ខណៈសម្បត្តិនៃការប្រើប្រាស់មួកការពារសុវត្ថិភាពដែរ។ប៉ុន្តែការដែលរូបលោកពុំទាន់ប្រើ គឺដោយសារតែអត់ទម្លាប់។ រតនៈបានអះអាងថា៖ "ខ្ញុំក៏ដឹងអំពីគុណសម្បត្តិរបស់មួកដែរ តែខ្ញុំអត់ទម្លាប់ពាក់។ ប៉ុន្តែពេលនេះត្រូវតែពាក់"។ លោកបានឱ្យដឹងថា ពីមុនលោកមិនពាក់ដោយសារតែខ្ជិលចំណាយលុយទិញមួក តែពេលនេះ បើមិនទិញទេនោះ នឹងអស់លុយច្រើនជាងមុនដោយសារតែប៉ូលីសផាក។ លោកក៏អះអាងស្រដៀងគ្នា នឹងកញ្ញាស៊ីថនដែរថា ការពាក់មួក អាចជួយបានច្រើន តែដោយសារតែលោកមិនទម្លាប់ លោកហាក់មានអារម្មណ៍ធ្ងន់ៗក្បាល។ ប៉ុន្តែវាក៏ជួយការពារក្បាល និងត្រចៀកបាន"។ ជាមួយគ្នានោះ លោកបានធ្វើការអំពាវនាវ ឱ្យអ្នកលក់មួកទាំងអស់ គួរកុំឆ្លៀតឱកាសយកចំណេញពេក ពីព្រោះវាអាចធ្វើឱ្យមានការលំបាកដល់អ្នកក្រីក្របាន។ លោកក៏បានឱ្យដឹងថា នៅពេលនេះអ្នកលក់ខ្លះ កំពុងតែឆ្លៀតឱកាសយកចំណេញប្រាក់មែនទែន។

តាមរបាយការណ៍ព័ត៌មាន ជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅកម្ពុជា ដែលទើបចេញផ្សាយប្រចាំខែសីហា ឆ្នាំ២០០៨ កន្លងទៅនេះ បានឱ្យដឹងថា នៅក្នុងរយៈពេលមួយខែនេះ គឺមានជនរងគ្រោះថ្នាក់ចរាចរណ៍សរុបចំនួន១៨២៨នាក់ ក្នុងនោះ ៥៥១នាក់របួសធ្ងន់ធ្ងរ និងស្លាប់១២៤ នាក់។ របាយការណ៍បញ្ជាក់ថា ជនរងគ្រោះលើសពី ៩០% មានគ្រោះថ្នាក់ គឺដោយសារមិនមានមួកសុវត្ថិភាពការពារនៅពេលបើកបរទោចក្រយានយន្ត។

February-2009.qxd 1/24/2009 4:39 PM Page 10

## បទយកការណ៍

# ឆ្នាំថ្មីហើយ! ទីផ្សារអចលនទ្រព្យកម្ពុជានៅតែជាប់គាំងដដែល

ខាន់ ភីរម្យ

អ្នកប្រកបរបររកទទួលទានខាងអចលនទ្រព្យ បានអះអាងថា មកដល់ដើមឆ្នាំថ្មី ទីផ្សារអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជានៅមិនទាន់មានសញ្ញាពីការងើបឡើងវិញនៅឡើយទេ។ អ្នកជំនាញខ្លះបានធ្វើការវាយតម្លៃថា វាត្រូវការពេលវេលាយ៉ាងហោចណាស់មួយឆ្នាំ។ ចំណែកអ្នកវិភាគខ្លះទៀតអះអាងថា វិស័យនេះត្រូវការពេលយ៉ាងតិចណាស់ក៏ ២ឆ្នាំដែរដើម្បីរីកចម្រើនឡើងវិញ។ ផ្ទុយពីនេះ អ្នកខ្លះទៀតថា មិនទាន់ហ៊ានទាយបានច្បាស់លាស់។

លោកគង់ វណ្ណសុធី ដែលជាអ្នកចាត់ការក្រុមហ៊ុនវិនិយោគទុនទ្រព្យសម្បត្តិអាទិភាពកម្ពុជាបានមានប្រសាសន៍ថា ទីផ្សារអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជានៅពេលនេះត្រូវការពេលវេលាយ៉ាងតិច ក៏ ១២ខែទៀតដែរ ដើម្បីជំរុញវា ឱ្យមានមានចលនាឡើងវិញ។ លោកបញ្ជាក់ថា: "ទីផ្សារដីធ្លី និងផ្ទះសម្បែងនៅកម្ពុជានៅពេលនេះស្ងាត់ឈឹង"។

លោកស៊ា ឆែលីង ប្រធានក្រុមហ៊ុនអចលនទ្រព្យវិសាល បានអះអាងថា នៅតាមបណ្តាផ្លូវពាណិជ្ជកម្មធំៗ មានជាអាទិ៍ នៅតាមមហាវិថីមុនីវង្ស និងនរោត្តម និងព្រះសីហនុដំណើរការទិញដូរអចលនទ្រព្យក្នុងប្រទេសនៅមានសកម្មភាពខ្លះ។ តែនៅកន្លែងផ្សេងៗទៀត ដែលស្ទើរតែទូទាំងប្រទេស គឺលែងកម្រើកកើតតែម្តង។ លោកបានអះអាងថា: "មកដល់ពេលនេះ ខ្ញុំឃើញ អ្នកដែលត្រូវការលុយប្រញាប់ខ្លះ គាត់បានប្រកាសបញ្ចុះតម្លៃរហូតដល់ទៅ៥០%ទៅហើយ ប៉ុន្តែនៅតែអត់ឃើញមានអ្នកមកទិញ។ បើតាមព័ត៌មានដែលខ្ញុំទទួលដោយសារប្រញាប់លុយកាក់ខ្លាំងពេក ម្ចាស់ដីខ្លះនៅតំបន់បឹងកេងកងនេះ បានបញ្ចុះតម្លៃមកនៅត្រឹម ១៨០០ ដុល្លារប៉ុណ្ណោះនៅក្នុងមួយម៉ែត្រការ៉េ"។ លោកស៊ា ឆែលីង មានប្រសាសន៍បញ្ជាក់ទៀតដែរថា គិតមកដល់ពេលនេះតម្លៃដីនៅក្នុងប្រទេស ពិសេសនៅទីក្រុងភ្នំពេញតាមដងផ្លូវសំខាន់ៗ ក៏ដូចជា នៅតំបន់បឹងកេងកង នៅតែមានតម្លៃពី ៥០០០ ដុល្លារ ទៅ ៧០០០ដុល្លារ នៅក្នុងមួយម៉ែត្រការ៉េ ប៉ុន្តែសំខាន់គឺមិនមានអ្នកទិញ។ លោកបានបន្តថា តម្លៃដីនៅដដែល គ្រាន់តែលក់អត់ចេញ។ ដូច្នេះសម្រាប់អ្នកត្រូវការលក់បន្ទាន់ គឺមានតែបញ្ចុះតម្លៃ។



តម្លៃអចលនទ្រព្យពឹងផ្អែកទាំងស្រុងលើសន្ទុះសេដ្ឋកិច្ច

Photo : S. Philong

### មូលហេតុនៃការធ្លាក់ចុះតម្លៃអចលនទ្រព្យនៅក្នុងប្រទេស

**ទីផ្សារអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជាបានកញ្ជ្រោលឡើងយ៉ាងខ្លាំងក្លានៅពាក់កណ្តាលឆ្នាំ២០០៧ ប៉ុន្តែ ៦ខែក្រោយមក វាបានចាប់ផ្តើមស្ងប់ស្ងាត់បន្តិចម្តងៗ រហូតមកដល់ពេលបច្ចុប្បន្ននេះ។ លោកស៊ឹង ប៊ុណ្ណា ប្រធានសមាគមអ្នកវាយតម្លៃអចលនវត្ថុជាតិកម្ពុជា បាននិយាយថា ការជាប់គាំងនៃទីផ្សារអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជានាពេលសព្វថ្ងៃនេះ បានកើតមានឡើងដំបូងនៅពេលដែលប្រទេសកម្ពុជារៀបចំដំណើរការបោះឆ្នោត និងបន្ទាប់មកដំណើរការនៃការរៀបចំបង្កើតរដ្ឋាភិបាលថ្មី ហើយវាបានបន្តជាប់គាំងទៀត ដោយសារតែវិបត្តិនៅព្រំដែនកម្ពុជាជាមួយប្រទេសថៃ ហើយចុងក្រោយនេះ គឺការរីករាលដាលនៃវិបត្តិហិរញ្ញវត្ថុពាសពេញពិភពលោកដែលចាប់ផ្តើមដំបូងពីប្រទេសអាម៉េរិក។ លោកបញ្ជាក់ថា: "ទីផ្សារអចលនទ្រព្យនៅក្នុងប្រទេសនេះត្រូវពឹងផ្អែកទាំងកត្តាក្នុង និងកត្តាខាងក្រៅ"។**

ផ្អែកតាមស្ថានការណ៍បែបនេះ លោកឆែលីង បានព្យាករណ៍ថា ទីផ្សារអចលនទ្រព្យ នៅក្នុងប្រទេសអាចត្រូវចំណាយពេលវេលាខ្លះដើម្បីស្តារឡើងវិញយូរជាងលោកវណ្ណ សុធី ។

លោកឆែលីង ក៏បានអះអាងថា: "ដើម្បីស្តារឡើងវិញបាននោះ កម្ពុជាប្រហែលជាត្រូវការពេលវេលារហូតដល់ទៅ ២ឆ្នាំដែរ"។

អ្នកផ្សាយដំណឹងលក់ផ្ទះនៅលើទំព័រកាសែតកោះសន្តិភាពមួយរូបដែលប្រាប់ថា ឈ្មោះសម្បត្តិ បាននិយាយឱ្យដឹងថា គាត់បានប្រកាសលក់ផ្ទះល្វែង ១កន្លែង មួយជុង នៅម្តុំអូរបែកក្អម អស់រយៈពេលប្រមាណជា ២ខែ មកហើយ ប៉ុន្តែនៅមិនទាន់មានអ្នកទាក់ទងមកសោះ។ អ្នកស្រីបានបញ្ជាក់បន្ថែមថា: "ផ្ទះរបស់ខ្ញុំពីមុន គេហ៊ានឱ្យ១០០០០០ដុល្លារហើយ ប៉ុន្តែខ្ញុំអត់លក់។ ឥឡូវបើឱ្យខ្ញុំតែ ៧០០០០ ដុល្លារខ្ញុំលក់ហើយ"។ រីឯអ្នកផ្សាយដំណឹងលក់ផ្ទះម្នាក់ទៀតដែលសុំមិនបញ្ចេញឈ្មោះ បានឱ្យដឹងថា គាត់បានប្រកាសលក់ដីរបស់គាត់មួយកន្លែងនៅតាមផ្លូវជាតិលេខ៤ ម្តុំជម្ពូវ័នតាំងតែពីខែតុលា ឆ្នាំទៅមកម្ល៉េះ តែនៅពុំទាន់លក់ដាច់ដដែល។ លោកបានឱ្យដឹងថា ដីនោះពីមុន មានតម្លៃមួយការ៉េ ជិត ២០០ដុល្លារតែពេលនេះ គាត់លក់ត្រឹមតែជាង ៥០ ដុល្លារ តែប៉ុណ្ណោះ តែលក់មិនទាន់ចេញ។

ពាក់ព័ន្ធជាមួយនឹងទីផ្សារអចលនទ្រព្យនេះកាលពីចុងឆ្នាំកន្លងទៅ លោកស៊ឹង ប៊ុណ្ណា ប្រធានសមាគមអ្នកវាយតម្លៃអចលនវត្ថុជាតិកម្ពុជា ក៏ធ្លាប់បានធ្វើការវាយតម្លៃថា តម្លៃអចលនទ្រព្យគឺនឹងអាចស្តារឡើងវិញនៅក្នុងរយៈពេលដល់ទៅ៦ខែ។ ប៉ុន្តែនៅពេលនេះ លោកបានអះអាងឡើងវិញថា មិនអាចវាយតម្លៃបានថា ពេលណាពិតប្រាកដ។ លោកបានបញ្ជាក់ដែរថា: "ទីផ្សារអចលនទ្រព្យនៅពេលនេះ វាប្រៀបបានទៅនឹងអណ្តូងដែលមើលលែងឃើញបាត។ ដូច្នេះយើងមិនអាចដឹងថា ទឹកអណ្តូងនោះជម្រៅណាដែរ"។

លោកហាក់ ប៊ុនថា នាយកក្រុមហ៊ុនអចលនទ្រព្យ បានឱ្យដឹងថា សម្រាប់អ្នកដែលមានអចលនទ្រព្យគួរតែរក្សាទ្រព្យនោះទុកសិន។ តម្លៃអចលនទ្រព្យវានឹងមិនធ្លាក់រហូតនោះទេ។ លោកបានឱ្យដឹងថា: "អចលនទ្រព្យ វាធ្លាក់ដោយសារតែយើងត្រូវការលុយ តែបើយើងមិនលក់វានៅតែដដែល"។

ទន្ទឹមពេលដែលទីផ្សារទិញលក់អចលនទ្រព្យក្នុងប្រទេសកំពុងធ្លាក់ចុះនោះ បណ្តាក្រុមហ៊ុនអចលនទ្រព្យមួយចំនួនបានរួបរួមគ្នាដើម្បីរៀបចំឱ្យទៅជាសមាគមមួយថ្មី ដែលហៅថាសមាគម អភិវឌ្ឍន៍អចលនទ្រព្យនៃកម្ពុជា កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០៨កន្លងទៅនេះ ។

លោកគង់ វណ្ណសុធី ដែលត្រូវបានតែងតាំងជាអ្នកសម្របសម្រួលកិច្ចការសមាគមនោះ បានឱ្យដឹងថា ក្នុងកិច្ចប្រឹងប្រែងក្នុងការជួយដល់ដំណើរការអភិវឌ្ឍន៍ទីផ្សារអចលនទ្រព្យ និងដំណើរការអភិវឌ្ឍន៍ប្រទេសកម្ពុជានោះ ក្រុមហ៊ុនអចលនទ្រព្យ ចំនួន ៣០ ក៏បានស្រុះស្រួលគ្នា បង្កើតសមាគមនេះឡើងកាលពីពាក់កណ្តាលខែកន្លងទៅជាមួយនឹងគោលបំណងមួយចំនួន មានដូចជាការប្រមូលព័ត៌មានពីទីផ្សារ ការសម្របសម្រួលនូវទំនាក់ទំនងក្រុមហ៊ុន និងរដ្ឋាភិបាលជាដើម។

វត្តមាននៃការបង្កើតសមាគមនេះ កើតមានឡើងក្រោយពេលដែលសមាគមអ្នកវាយតម្លៃអចលនវត្ថុជាតិកម្ពុជាមួយបានត្រូវគេបង្កើតឡើង។ ប៉ុន្តែទោះបីជាយ៉ាងណា ប្រធានសមាគមអ្នកវាយតម្លៃអចលនវត្ថុជាតិកម្ពុជា អះអាងថាសមាគមទាំងពីរនេះដើរតួនាទីខុសគ្នា។ ដូច្នេះហើយក្រុមហ៊ុនរបស់លោកក៏ជាសមាជិកនៃសមាគមថ្មីដែលទើបបង្កើតនេះដែរ។ ហើយលោកក៏មានតួនាទីជាអគ្គលេខាធិការរងនៃសមាគមថ្មីនេះផងដែរ។

លោកស៊ឹងប៊ុណ្ណា ជាប្រធានក្រុមហ៊ុនអចលនទ្រព្យមួយ ហើយបច្ចុប្បន្ន គឺជាប្រធានសមាគមអ្នកវាយតម្លៃអចលនវត្ថុជាតិកម្ពុជា ក៏អះអាងថា: "សមាគមទាំងពីរមានតួនាទីខុសគ្នា ហើយមិនប៉ះទង្គិចគ្នាទេ។ ខាងសមាគមអភិវឌ្ឍន៍អចលនទ្រព្យកម្ពុជាដើរតួនាទីជាអ្នកផលិត។ចំណែកសមាគមអ្នកវាយតម្លៃអចលនវត្ថុជាតិកម្ពុជា ធ្វើជាអ្នកបំពេញសេវាកម្ម"។ លោកបានឱ្យដឹងថា រហូតមកដល់ពេលនេះនៅប្រទេសកម្ពុជា យើងកំពុងព្យាយាមអភិវឌ្ឍន៍ទាំងអស់គ្នា។ រដ្ឋាភិបាល ក៏ប្រឹងប្រែងអភិវឌ្ឍន៍។ ក្រុមហ៊ុនក៏កំពុងតែអភិវឌ្ឍន៍។ ដូច្នេះសមាគមនេះនឹងជួយយើងឱ្យទទួលបានជោគជ័យទាំងអស់គ្នា។ ទាក់ទងនឹងសភាពការណ៍ទីផ្សារអចលនទ្រព្យនៅក្នុងប្រទេស ដែលគេអះអាងថា កំពុងតែដាំក្បាលចុះនោះ លោកស៊ឹង ប៊ុណ្ណា បានអះអាងថាសមាគមនេះនឹងអាចជួយបាន នៅពេលអនាគតតែនៅពេលនេះ វានៅមិនទាន់អាចជួយអ្វីបានទេដោយសារតែទើបតែបង្កើត។ លោកបានប្រាប់ឱ្យដឹងថា អ្វីៗ នៅមិនទាន់ដំណើរការដោយរលូននៅឡើយ។ វាកំពុងតែស្ថិតនៅក្នុងដំណាក់កាលនៃពេលចាប់ផ្តើម ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ វានឹងមានប្រយោជន៍សម្រាប់ការធានានូវលំនឹងនៅក្នុងទីផ្សារអចលនទ្រព្យនៅកម្ពុជា។ លោកក៏បានបញ្ជាក់បន្ថែមថា: "យើងមិនទាន់បានជជែកគ្នានៅឡើយទេអំពីបញ្ហានេះ។ តែខ្ញុំជឿថា យើងនឹងជជែកគ្នាអំពីបញ្ហានេះនៅពេលអនាគតខាងមុខ"។

### សមាគមអភិវឌ្ឍន៍អចលនទ្រព្យនៅប្រទេសកម្ពុជា

**សមាគមអភិវឌ្ឍន៍អចលនទ្រព្យនៃកម្ពុជាបង្កើតឡើង គឺដើម្បីជំរុញដំណើរការអភិវឌ្ឍន៍ប្រទេស និងទីផ្សារអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជា។ លោកគង់ វណ្ណសុធី អ្នកចាត់ការរដ្ឋបាលនៃសមាគមបានឱ្យដឹងថា សមាគមត្រូវបានបង្កើតដោយក្រុមហ៊ុនអចលនទ្រព្យចំនួនប្រមាណ ៣០ ទាំងក្នុងស្រុក និងមកពីកូរ៉េ បារាំង ហុងកុង និងអាម៉េរិក ហើយកំពុងធ្វើអាជីវកម្មនៅកម្ពុជា។ លោកបានបញ្ជាក់ថា: "វាគឺជាសមាគមពាណិជ្ជកម្មថ្មីទើបបង្កើតសម្រាប់បម្រើប្រយោជន៍ឱ្យសហគ្រាសអភិវឌ្ឍន៍អលចនទ្រព្យ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា"។ លោកបានឱ្យដឹងថា សមាគមបង្កើតនៅថ្ងៃទី១៩ ធ្នូ ឆ្នាំ២០០៨ ដើម្បីធ្វើជាតំណាងឱ្យផលប្រយោជន៍នៃសហគ្រាសអភិវឌ្ឍន៍ អចលនទ្រព្យ និងសហគ្រាសដែលមានសកម្មភាពពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍អចលនទ្រព្យ។ សមាគមមានតួនាទីលើកកម្ពស់ការអនុវត្តន៍ការទទួលខុសត្រូវរបស់ក្រុមហ៊ុនអាជីវកម្មអភិវឌ្ឍន៍អចលនទ្រព្យចំពោះសង្គម និងបរិស្ថាន ជួយសម្របសម្រួលអន្តរកម្មរវាងសមាជិក ប្រមូលព័ត៌មាន ស្រាវជ្រាវ និងរាយការណ៍ស្តីអំពីបញ្ហាដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍អចលនទ្រព្យ ព្រមទាំងដើរតួនាទីជាអ្នកធ្វើទំនាក់ទំនងជាមួយអាជ្ញាធរ អង្គការពាណិជ្ជកម្ម សមាគមអាជីវកម្មនានា និងអង្គការដទៃទៀត ដែលទាក់ទងទៅនឹងបរិយាកាសវិនិយោគផ្សេងៗ។**

February-2009.qxd 1/24/2009 4:39 PM Page 12

# កសិកម្ម

# បទពិសោធន៍ការដាំដំណាំ ខ្ទឹមស្លឹក

**ទស្សនាវដ្តីកសិករ លេខ ១១៩**


Photo : P. Samphy

អ្នកមីងអ៊ឹ លាប មានអាយុ ៣៧ឆ្នាំ ជាកសិកររស់នៅភូមិស្វាយយា ឃុំស្វាយយា ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង បានចែករំលែកបទពិសោធន៍ដាំខ្ទឹមស្លឹក ដែលជាគំនិតគាត់កែច្នៃដោយខ្លួនឯងថា:

ពូជខ្ទឹមដែលគាត់ដាំ គឺជាពូជខ្ទឹមក្នុងស្រុក ពីព្រោះវាមានភាពធន់នឹងជំងឺបានល្អប្រសើរ ។ គាត់អាចដាំខ្ទឹម២ដង ក្នុងមួយឆ្នាំ គឺនៅរដូវប្រាំង និងវស្សា ។

មុននឹងដាំ គាត់បានកាប់ហាលដីទុក រយៈពេលពី៥ ទៅ១០ថ្ងៃសិន ។ បន្ទាប់មកត្រូវលើករងដែលមានទទឹងប្រហែល ០,៧ម៉ែត្រ និងបណ្ដោយ ទៅតាមប្រវែងដី និងចន្លោះពីររងមួយទៅមួយ មានប្រវែង ៥តឹក ។ នៅរដូវប្រាំង គាត់ធ្វើរងទាប ចំណែករដូវវស្សា គាត់ធ្វើរងឱ្យខ្ពស់ ដើម្បីកុំឱ្យជាំទឹកខ្លាំងពេក ដែលនាំឱ្យកើតជំងឺរលួយគល់ ។ ពីលើរង គាត់ដាក់នូវជីកំប៉ុស្ត និងលាមកសត្វពុកផុយទ្រាប់បាតរង ។

ក្រោយពីរៀបចំរងរួចរាល់ គាត់ក៏យកពូជខ្ទឹមដែលបានត្រៀមរួចទៅដាំ ដោយទុកនូវចន្លោះគុម្ព ១,៥ សង់ទីម៉ែត្រ ។ គាត់ដាំខ្ទឹមស្លឹកនាពេលល្ងាចត្រជាក់ ដើម្បីកុំឱ្យស្រពោនដើម ។

ក្រោយពីដាំហើយ ដើម្បីឱ្យខ្ទឹមបានផលល្អ គាត់ក៏បានយកចិត្តទុកដាក់ក្នុងការថែទាំវា ដូចជាស្រោចទឹក ធ្វើស្មៅ ដាក់ជី-ល- ។ ការស្រោចទឹក ត្រូវធ្វើពីរដងក្នុងមួយថ្ងៃ ។ គាត់ធ្វើស្មៅចំនួន ៣ដង ចាប់ពីដាំរហូតដល់ការប្រមូលផល ។ លើកទី១ ក្រោយពេលដាំបាន ៧ ទៅ១០ថ្ងៃ លើកទី២ គឺនៅពេលដាំបានរយៈពេល ២៥ថ្ងៃ និងលើកទី៣ នៅមុនពេលប្រមូលផលរយៈពេលមួយអាទិត្យ ។ គាត់ត្រូវដាក់ជីលាមកសត្វពុកផុយទ្រាប់បាត និងបំប៉ន ក្រោយពេលដាំបាន១០ថ្ងៃ ដាក់នៅតាមចន្លោះគុម្ពមួយៗ ហើយគាត់ស្រោចទឹក ដោយលាយជាមួយជីកំប៉ុស្តទឹក នៅពេលខ្ទឹម អាយុបាន ១៥ថ្ងៃ រហូតដល់ខ្ទឹមអាយុបាន ២៥ថ្ងៃ ទើបឈប់ស្រោចជីកំប៉ុស្តទឹក ។

នៅពេលខ្លះ គាត់បានយកផេះមកបាចនៅតាមរងខ្ទឹមដើម្បីជួយបន្ថែមជីជាតិដល់ដី ។ ចំពោះសត្វល្អិតពុំមានបញ្ហាទេ ព្រោះខ្ទឹមមានក្លិនក្រពុល ដែលធ្វើឱ្យសត្វល្អិតមិនហ៊ានមកជិត ។ តែវាច្រើន កើតជំងឺរលួយគល់ និងរលួយស្លឹកនៅរដូវវស្សា ដែលមានភ្លៀងជោគជាំ ។ នៅពេលពិនិត្យឃើញមានជំងឺនេះ គាត់ដកចោលនូវគុម្ពណាដែលកើតជំងឺនោះ ចោល ដើម្បីកុំឱ្យឆ្លងទៅដល់គុម្ពដទៃទៀត ។

ក្រោយពីដាំបាន ៣៥ ទៅ ៤៥ថ្ងៃ គាត់អាចប្រមូលផលបាន តែទុក ១រង ដើម្បីធ្វើពូជដាំបន្តទៀត ។

## បរិស្ថាន

### ធ្យូងពូតបន្ថយសំរាម

ចាប់តាំងពីឆ្នាំ២០០៧ ក្រុមថាមពលកកើតឡើងវិញ បរិស្ថាន និងសាមគ្គីភាព អង្គការ Geres បានបង្កើតកម្មវិធីមួយ គឺការធ្វើធ្យូងពូតនៅខណ្ឌស្ទឹងមានជ័យ រាជធានីភ្នំពេញ ។ លោកលី ម៉ាត់ហៀត អ្នកសម្របសម្រួលគម្រោង មានប្រសាសន៍ថា: សម្រាប់គម្រោងនៃការធ្វើធ្យូងពូតនេះ យើងមានគោលបំណងសំខាន់ៗ មានដូចជាទីមួយ យើងចង់កាត់បន្ថយការប្រែប្រួលអាកាសធាតុ ។ទីពីរ យើងចង់បន្ថយការកាប់បំផ្លាញព្រៃឈើ ។ ទីបី យើងចង់កាត់បន្ថយសំរាម ដែលមាននៅក្នុងក្រុងភ្នំពេញ ។ ហើយទីបួន យើងចង់ផ្តល់ការងារដល់ប្រជាជនក្រីក្រ ជាពិសេស ប្រជាជននៅតំបន់គំនរសំរាមស្ទឹងមានជ័យ ដែលមានរបរដើរប្រមូលអេតចាយ ឱ្យប្រមូលវត្ថុធាតុដើមយកមកធ្វើធ្យូងនេះ ។


Photo : Geres

ចំណែកវត្ថុធាតុដើម សម្រាប់ធ្វើធ្យូងពូតនេះមានច្រើន ដូចជាក្រដាសចោល ដើមអាកាស្យា ឬដើមឈើគ្រប់ប្រភេទ-ល- ហើយបច្ចេកទេសធ្វើទៀតសោតមានផ្សេងៗគ្នា ។ ប៉ុន្តែអង្គការ Geres ផ្តោតជាសំខាន់ គឺការធ្វើធ្យូងពូត ពីសំបកដូង ស្រកីដូង ឬត្រឡោកដូង ដែលជាសំរាម ។

លោកលី ម៉ាត់ហៀត បន្តថា ប្រជាជនធម្មតាគាត់ប្រហែលជាមិនអាចធ្វើធ្យូងពូតនេះបានទេ ព្រោះវាត្រូវការបច្ចេកទេសសាំញ៉ាំ និងឧបករណ៍ទំនើបខ្លះ ។ ទោះជាយ៉ាងនេះក្តី ធ្យូងពូតគឺមានគុណភាពលើសពីធ្យូងធម្មតា ដែលវាប្រៀបបាននឹងធ្យូងថ្មដោយនៅពេលដុតវា គឺមិនមានផ្សែង មិនមានផ្សែងខ្មៅ ឬអណ្តាតភ្លើងក្រហមដូចធ្យូងធម្មតាឡើយ ។ ហើយធ្យូងពូតនេះ គេនឹងមានចរាចរណ៍នៅលើទីផ្សារនៅ ៦ខែ ខាងមុខទៀត ។ **សំភី**



# សុខភាព

# ស្ត្រេស៍ ឬការតានតឹងអារម្មណ៍មិនមែនជាអាការៈសាមញ្ញពេកទេ

**ជាត សំភី**


Photo : P. Samphy

បើតាមប្រសាសន៍របស់អ្នកស្រីវេជ្ជបណ្ឌិតចក់ ធីតា ឯកទេសរិកលវិទ្យា ប្រចាំមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានឱ្យដឹងថា:

ស្ត្រេស៍ ជាអារម្មណ៍ដែលតានតឹង ខឹងសម្បានឹងធ្វើអ្វីមិនបានសម្រេច ពោលគឺ នៅពេលមនុស្សយើងមិនបានជោគជ័យក្នុងការដោះបញ្ហា ។ ស្ត្រេស៍វាធ្វើឱ្យមនុស្សយើង គិតក្នុងផ្លូវអវិជ្ជមាន និងពិបាកចិត្ត ដែលវាបណ្តាលឱ្យតានតឹងសាច់ដុំ ធ្វើឱ្យសាច់ដុំឈឺចាប់ ។ បន្ទាប់មកវាធ្វើឱ្យយើងឈឺក្បាល ងាយខឹងបារម្ភ អស់កម្លាំង និងគិតច្រើនដែលធ្វើឱ្យគេង មិនលក់ ។ ម្យ៉ាងទៀតវាជះឥទ្ធិពល លើសរីរាង្គផ្សេងៗទៀតឱ្យស្ពឹកស្រពន់ ឬឈឺក ។ អ្នកកើតស្ត្រេស៍អាចញ័រ តឹងណែនដើមទ្រូង ពិបាកដកដង្ហើម និងក៏ឈឺខ្នង ។ គេមានអាការៈចង់ក្អួត និងឈឺក្រពះឈឺ ឈឺអវយវៈ និងសាច់ដុំជាដើម ។

មូលហេតុនៃស្ត្រេស គឺមានច្រើនដែលអាស្រ័យទៅលើប្រភេទមនុស្ស ក៏ដូចជាស្ថានភាពរស់នៅរបស់ពួកគេ: អ្នកធ្វើការងារដែលមាននូវការទទួលខុសត្រូវច្រើនពេក ប្រាក់ខែទាប ធ្វើការច្រើនម៉ោងពេក ព្រមជាមួយនិងមហិច្ឆតាខ្ពស់ពេក-ល- ។ រីឯសិស្សរៀនមិនយល់ ពិបាកផ្លូវអារម្មណ៍ និងមានសំពាធមុនពេលប្រឡងជាដើម ។ បើនៅក្នុងគ្រួសារ បញ្ហាដែលធ្វើឱ្យមានស្ត្រេស៍ មានដូចជាគ្រួសារនោះមានជម្លោះ អំពើហិង្សាក្នុងគ្រួសារ របៀបអប់រំកូន តឹងពេក-ល- ។ ស្ត្រេស៍ដែលបណ្តាលមកពីសង្គម មានដូចជា មនុស្សជួបសោកនាដកម្ម ជីវភាពរស់នៅក្របញ្ហាសេដ្ឋកិច្ចធ្លាក់ចុះ ចរាចរណ៍កកស្ទះ សុវត្ថិភាពមិនធានាមានអំពើចោរកម្ម និងប្លន់ច្រើន ឬក៏វប្បធម៌ និងជំនឿក្នុងសង្គមតឹងរ៉ឹងពេកជាដើម ។

ចំណែកវិធីដោះស្រាយស្ត្រេស៍ វាអាស្រ័យទៅតាមសមត្ថភាពរបស់មនុស្សម្នាក់ៗ ក្នុងការបំបាត់មូលហេតុរបស់វានេះដូចជាបើមានការងារច្រើន យើងអាចរៀបចំកាលវិភាគវា ។ ម្យ៉ាងទៀត យើងអាចដោះស្រាយវាដោយការដើរកំសាន្ត និងធ្វើលំហាត់ប្រាណ ។ យើងអាចធ្វើលំហាត់ដង្ហើម ។ក្នុងមួយថ្ងៃ យើងដកដង្ហើមវែងឱ្យបាន១០នាទី ដំបូងស្រូបចូលខ្យល់តាមច្រមុះ រួចក៏រាប់មួយ ពីរ បី ក្នុងអារម្មណ៍ បន្ទាប់មកបញ្ចេញវិញ យឺតៗ តាមមាត់ ។

អ្នកស្រីវេជ្ជបណ្ឌិត មានអនុសាសន៍ថា: "បើយើងដោះស្រាយស្ត្រេស៍មិនបាន គួរទៅរកគ្រូពេទ្យឯកទេសឱ្យជួយព្យាបាល ព្រោះបើទុកយូរធ្ងន់ទៅៗ វាអាចប៉ះពាល់ដល់សុខភាព និងមានជំងឺផ្លូវចិត្ត ។

# សេដ្ឋកិច្ច

# ឥណទានខ្នាតតូចកំណត់ការប្រាក់ដដែល

ឆ្នាំ២០០៩ ស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងប្រទេស គឺមិនអាចបញ្ចុះអត្រាការប្រាក់ជូនដល់អតិថិជនបានទេ ដោយសារតែវិបត្តិហិរញ្ញវត្ថុពិភពលោក ។

លោកហួត អេងតុង ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា មានប្រសាសន៍ថា: "នាឆ្នាំ២០០៨ យើងយក ២,៥% នៅក្នុងមួយខែ ឆ្នាំ២០០៩ យើងយកការប្រាក់ដដែល" ។ លោកបានឱ្យដឹងថា រៀងរាល់ឆ្នាំ ស្ថាប័នមីក្រូហិរញ្ញវត្ថុនៅប្រទេសកម្ពុជា គឺមានគម្រោងបញ្ចុះអត្រាការប្រាក់ ជាប្រចាំ ហើយនៅក្នុងឆ្នាំថ្មីនេះ ស្ថាប័នទាំងនោះក៏មានបំណងដែរ តែមិនអាចធ្វើបាន ។ លោកបញ្ជាក់ថា: "យើងគ្រោងបញ្ចុះការប្រាក់ពី០,១ ទៅ០,៣% ប៉ុន្តែឆ្នាំ២០០៩ គឺមិនអាចចុះបានដាច់ខាត" ។ តាមប្រសាសន៍របស់ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សម្រាប់ឆ្នាំ២០០៩នេះ ការរក្សាការប្រាក់ដដែល វាជាដំណឹងល្អមួយទៅហើយ ដោយសារពេលនេះស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់ កំពុងប្រឈមមុខនឹងកង្វះខាតទុន ហើយសម្រាប់អ្នកដែលទទួលបាន ក៏ប្រឈមមុខនឹងការទាមទារតម្លើងអត្រាការប្រាក់របស់គេផងដែរ ។ ប្រភពទុនសំខាន់បំផុតរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលកំពុងតែផ្តល់សេវាឥណទានខ្នាតតូចដល់ប្រជាពលរដ្ឋកម្ពុជានោះ គឺជាង៩៥% ទទួលពីខាងក្រៅ ពោលគឺនៅអឺរ៉ុប និងអាមេរិក ។ ប៉ុន្តែនាពេលនេះ បណ្តាប្រទេសទាំងនោះក៏កំពុងប្រឈមមុខនឹងវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរ និងមិនទាន់ស្តាររួច ។

លោកបន្ថែមថា ឆ្នាំ២០០៨ បរទេសទារការប្រាក់ពីមីក្រូហិរញ្ញវត្ថុតែ ៧% ទៅ៨,៥% តែឆ្នាំ២០០៩ ទារ ពី ៩% ទៅ ១០% និងខ្លះរហូតដល់ ១២% ។

**ខាន់ ភិរម្យ**



Photo : P. Samphy

### សាវតារស្ថាប័នមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

លោកហួត អេងតុង មានប្រសាសន៍ថា ស្ថាប័នមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសបានចាប់កំណើតនៅទសវត្សរ៍នៃឆ្នាំ១៩៩០។ មកដល់ពេលនេះកម្ពុជា មានស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិចំនួន ១៨ និងស្ថាប័នដែលទើបតែចុះបញ្ជីមួយចំនួនទៀត។ តាមតួលេខពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០០៨ អតិថិជនរបស់មីក្រូហិរញ្ញវត្ថុទាំងអស់មាន ៧៦៧១៦៤នាក់។

លោកតុង បានឱ្យដឹងថា នាពេលសព្វថ្ងៃនេះ គេចាត់ទុកថា វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា កំពុងតែរីកចម្រើនដោយសារតែមានការព្យាយាមកាត់បន្ថយការប្រាក់ជាប្រចាំដល់អតិថិជន ពោលគឺពីជាង ១០% នៅក្នុងមួយខែមកនៅត្រឹមតែ២,៥% ហើយចំនួនស្ថាប័នមីក្រូហិរញ្ញវត្ថុ និងអតិថិជនរបស់ពួកគេក៏មានការកើនឡើងជាលំដាប់ផងដែរ។

February-2009.qxd 1/24/2009 4:39 PM Page 14





Photo : S. Philong

# មាឃបូជា រំឭកមហាសន្និបាត សង្ឃលើកដំបូង

**ខាន់ ភីរម្យ**

មាឃបូជា ដែលនឹងប្រារព្ធនៅថ្ងៃ ១៥កើត ខែមាឃតាមប្រតិទិនចន្ទគតិ ត្រូវនឹងថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំសកលខាងមុខ គឺជាថ្ងៃរំឭកដល់មហាសន្និបាតសង្ឃលើកទីមួយ ។ នេះបើតាមសង្ឃដីកា ព្រះតេជគុណឃី សុវណ្ណរតនាសកលវិទ្យាធិការរងនៅពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ្យ ។

ព្រះតេជគុណមានសង្ឃដីកាដែរថា នៅក្នុងពេលដែលព្រះសង្ឃទាំងអស់និមន្តជួបជុំគ្នាជាលើកទីមួយ បើតាមឯកសារ បានឱ្យដឹងថា គឺមានសង្ឃចំនួន២០០អង្គ បានចូលរួមដោយនៅក្នុងពេលនោះ និងមានការប្រជុំពិភាក្សាពីព្រះធម៌ ព្រះវិន័យ និងព្រះសិក្ខាបទជាច្រើនទៀត ។

សម្រាប់ពិធីមាឃបូជាធ្វើនៅកម្ពុជា គឺព្រះសង្ឃ លោកអាចនិមន្តទៅជួបជុំគ្នានៅតាមកន្លែងសំខាន់ៗ ដូចជានៅមុខព្រះសក្យមុនីចេតិយក្រុងភ្នំពេញ ឬនៅមុខព្រះសក្យមុនីចេតិយថ្មីនៅភ្នំឧត្តុង ឬក៏នៅតាមវត្តអារាមជាដើមដើម្បីផ្តល់ពុទ្ធឱវាទ អប់រំដល់ពុទ្ធសាសនិកទូទៅពីផ្លូវធម៌ និងផ្លូវលោក ។

ព្រះតេជគុណឃី សុវណ្ណរតនា ក៏មានសង្ឃដីកាបន្តថា ចំពោះជនសាមញ្ញ គេអាចមកចូលរួមតាមរយៈការយកនូវគ្រឿងសក្ការៈបូជាសម្រាប់ ព្រះពុទ្ធបដិមាករ និងអាចនាំយកចង្ហាន់មកប្រគេនព្រះសង្ឃ ព្រមទាំងចូលរួមស្តាប់ធម៌ទេសនាដើម្បីតម្រង់កាយវាចាចិត្តទៅតាមផ្លូវកុសល ។

ព្រះតេជគុណមានសង្ឃដីកាបន្ថែមដែរថា : "អ្នកដែលចូលរួមពិធី នេះនឹងទទួលបាននូវបុណ្យកុសល និងការដុះខាត់កាយវាចាចិត្តដើម្បីកុសល និងលះបង់អំពើបាប" ។ ក្រៅពីនេះ នេះជាឱកាសជួបជុំគ្នាដើម្បីពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ និងសាមគ្គីភាពរវាងគ្នា និងគ្នាក្នុងចំណោមប្រជាជនផងដែរ ។

ដោយសារតែប្រទេសកម្ពុជា បានចាត់ទុកថា ព្រះពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ ។ ដូច្នេះហើយនៅថ្ងៃទី៩ ខែកុម្ភៈ ដែលជាថ្ងៃប្រារព្ធពិធីនេះ មន្ត្រីរាជការ និងកម្មករទាំងអស់បានទទួលការលើកទឹកចិត្តដោយការអនុញ្ញាតឱ្យឈប់សម្រាក ១ថ្ងៃ ។ ព្រះតេជគុណរតនា មានសង្ឃដីកាថា រហូតមកដល់ពេលនេះ ជាង៩០%នៃប្រជាពលរដ្ឋកម្ពុជាមានជំនឿទៅលើព្រះពុទ្ធសាសនា ។ ហេតុដូច្នេះហើយបានជាពិធីនានាដែលមានពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា គឺបានត្រូវលើកទឹកចិត្ត ។ ប៉ុន្តែទោះបីជាយ៉ាងណា កម្ពុជាក៏នៅតែគោរពសេរីភាពសាសនាដ៏ទៃផងដែរ ។

## អំណាន

### ស្នេហ៍ដូចជាមិនស្នេហ៍



មាលតីស្រលាញ់ម៉ានិត គឺមិនមែនមកពីម៉ានិតមានរូបសម្បត្តិល្អ មានទ្រព្យមហាសាល ឬក៏ធ្លាប់ទៅរៀនសូត្រនៅបារាំងនោះទេ ។ តែមកពីម៉ានិតជាមនុស្សស្លូតត្រង់ និងហ៊ានទទួលខុសត្រូវចំពោះការពិត ។ គ្រួសារម៉ានិតក៏ធ្លាប់ធ្វើឱ្យគ្រួសារមាលតីធ្លាក់ដុនដាបកាលពីអតីតកាល ។ នៅពេលជួបម៉ានិតម្តងៗ មាលតីមានអារម្មណ៍ខឹង ស្អប់ ខ្ពាញ់ និងសប្បាយក្នុងពេលតែមួយ ។ នាងស្អប់គេ តែនាងស្រលាញ់បទចម្រៀងដែលគេចូលចិត្ត ។ នាងខឹងគេ ប៉ុន្តែនាងរង់ចាំដំណើររបស់គេយ៉ាងអន្ទះសា ។ ទោះជាយ៉ាងណា មាលតីមិនដឹងថា ម៉ានិត មានរោគមហារីកឈាមដែលរុករានគេមួយថ្ងៃបន្តិចៗឡើយ ។

ស្នេហ៍ដូចជាមិនស្នេហ៍ ជាប្រលោមលោកដែលវិភាគយ៉ាងល្អិតល្អន់លើចិត្តសាស្ត្ររបស់មនុស្ស ជាពិសេសលើការគ្រប់គ្រងមនោសញ្ចេតនា...( ស្រលាញ់ ស្អប់ ការពិបាកក្នុងការសម្រេចចិត្ត និងការលើកលែងទោស...) ។

រឿងនេះនិពន្ធដោយលោកកាំណែល និងត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៧៥ ដែលមានកម្រាស់ ៦៤ទំព័រ ។

### រឿងកូនស្តេចដំរីស



នៅពេលធំដឹងក្តី នាងលំអងរំចេកឮតែអ្នកជិតខាងស្រែកថា : "មីកូនឥតឪពុក! កើតមកពុំច្រឡំនឹងគេ ! កើតមកមិនដឹងឪនៅឯណា?" ។ បន្ទាប់ពីបានដឹងពីសាវតាខ្លួនថា ជាកូនស្រីបង្កើតរបស់ស្តេចដំរីសមក ។ នាងលំអងរំចេកចាកចេញពីផ្ទះដើម្បីតាមរកឪពុកខ្លួន ។ នៅពេលបានជួបជុំ និងទទួលស្គាល់នាងលំអងរំចេកជាកូន ស្តេចដំរីសបានឱ្យនាងទៅរស់នៅក្នុងប្រាសាទមួយកណ្តាលទ្រូងព្រៃជាមួយខ្លួនដោយផ្គត់ផ្គង់នាងមិនឱ្យខ្វះអ្វីឡើយ ។

ថ្ងៃមួយនាងត្រូវព្រះមហាក្សត្រ មកដង្ហែនាងទៅនៅព្រះរាជវាំង ហើយអភិសេកនាងជាព្រះមហេសី ។ ស្តេចដំរីសជាឪពុកអន្ទះសាក៏តាមរកនាងគ្រប់ទីកន្លែង ។ ណាបាត់កូន ណាព្រួយបារម្ភ ណាកំហឹងឆាបឆេះពេញប្រាណ ស្តេចដំរីក៏វាយវាត់កំពែងព្រះរាជវាំងរហូតស្លាប់ខ្លួន ។

នេះជារឿងនិទានដ៏ពិរោះ សរសេរបានល្អ និងរចនាដោយរូបភាពយ៉ាងវិចិត្រដែលនឹងនាំកុមារទៅរកពិភពថ្មីមួយ ។ រឿងនេះបោះពុម្ពនៅឆ្នាំ២០០៥ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយដំរីស និងលក់តម្លៃ ២៨០០រៀល ។

**ហួត សុជាតា**





# ភូមា ប្រទេសគ្រប់គ្រងដោយយោធា





Photos : DR

**អាន ឡូរី ប៉ូរ៉េ**

ប្រទេសធំបំផុតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ក៏ជាប្រទេសបិទជិតបំផុតនៅក្នុងតំបន់ ។ ប្រទេសនេះក៏មាននូវចលនាប្រវត្តិសាស្ត្រដូចជាប្រទេសនានាជិតខាងក្នុងតំបន់ដែរ ដែលត្រូវធ្វើឱ្យរញ្ជួយដោយសារការស្រេកឃ្លាន របស់ព្រះមហាក្សត្រ នៅក្នុងតំបន់ និងការចង់បានអំពីសំណាក់ប្រទេសមួយចំនួនដែលមានចរិតជាអ្នកឈ្លានពាន ។

ពីអតីតកាល ព្រះរាជាណាចក្រ ប៉ាហ្កាន (Pagan) បានស្ថាបនាចក្រភពភូមាពិតប្រាកដលើកដំបូងនៅសតវត្សរ៍ទី១១ នៃគ្រិស្តសករាជ ។ នាចុងសតវត្សរ៍ទី១៣ មហន្តរាយក៏បានកើតមានឡើងដោយមានការលុកលុយពីជនជាតិម៉ុងហ្គោល ហើយបន្ទាប់ពីជនជាតិម៉ុងហ្គោចាកចេញ ព្រះមហាក្សត្រភូមា ក៏ខិតខំបង្រួបបង្រួមប្រទេស ។ ព្រះរាជាតាបាំងស្វេទី (Tabinshwehti) បានបង្កើតចក្រភពភូមាទី២នៅពាក់កណ្តាលសតវត្សរ៍ទី១៦ ប៉ុន្តែចក្រភពនេះបានដួលរលំប៉ុន្មានទសវត្សរ៍ក្រោយមកទៀត ។

សតវត្សរ៍ទី១៨ អាលួងប៉ាយ៉ា (Alaungpaya) ជាអ្នកស្ថាបនាអំណាចភូមា ។ លោកបានបង្ក្រាបការបះបោររបស់ជនជាតិមន ហើយប្រយុទ្ធប្រឆាំងជាមួយអាណានិគមអង់គ្លេស និងបារាំង ។ លោកបានស្ថាបនារាជធានីរ៉ង់ហ្គោន ។

ជនជាតិភូមាវាយដណ្តើមបានរាជាណាចក្រសៀម ប៉ុន្តែត្រូវដកថយទៅវិញដើម្បីទប់ទល់នឹងការវាយប្រហាររបស់ចិន ។ ពួកគេក៏ត្រូវបរាជ័យចំពោះកងទ័ពអង់គ្លេសបីដងក្នុងអំឡុងសតវត្សរ៍ទី១៩ ។ នេះជាហេតុផលដែលធ្វើឱ្យជនជាតិអង់គ្លេសធ្វើសមាហរកម្មប្រទេសភូមាក្នុងចក្រភពឥណ្ឌារបស់ពួកគេដោយលែងមានការតស៊ូបះបោរ ។

តាមពិត ការគ្រប់គ្រងរបស់អង់គ្លេសមានលក្ខណៈល្អចំពោះសេដ្ឋកិច្ច ប៉ុន្តែវាបំផ្លាញទៅដល់ផែនការសង្គម និងវប្បធម៌ ។ ពេលនោះគណបក្សនយោបាយនានាដែលមានភាពជាសត្រូវចំពោះវត្តមានរបស់ជនជាតិឥណ្ឌានៅតាមវាលស្រែ តាមដងទន្លេអ៊ីរ៉ាវ៉ាឌី កាន់តែរីកដុះដាលឡើង ។ លទ្ធិជាតិនិយមបានរីកចម្រើន ។ ទោះបីប្រទេសភូមាប្រែក្លាយទៅជាប្រទេសអាណានិគមអង់គ្លេស ដូចប្រទេសឥណ្ឌាក៏ប៉ុន្តែលទ្ធិប្រឆាំងនឹងអាណានិគមពុះកញ្ជ្រោល ។

### អ៊ុងសាន ស៊ូជី ជានរណា?



**អ្នកស្រីគឺជាកូនស្រីរបស់មេដឹកនាំជាតិនិយម និងកុំមុយនីស្តនិយម គឺលោកបូយូគេ អ៊ុងសាន (Bogyoke Aung San) ដែលបានប្រយុទ្ធដើម្បីឯករាជ្យភាពភូមា។ អ្នកស្រីចូលប្រឡូកក្នុងឆាកនយោបាយនៅឆ្នាំ១៩៨៨ ក្នុងការបង្កើតគណបក្សប្រឆាំង។ ក្រោយពីការបោះឆ្នោត អ្នកស្រីត្រូវជាប់នៅក្នុងមន្ទីរឃុំឃាំង និងស្ថិតនៅក្រោមការឃ្លាំមើលជាប់ជាប្រចាំ។ អ្នកស្រីបានទទួលនូវមហារង្វាន់កិត្តិយសជាច្រើន ក្នុងនោះរួមបញ្ចូលទាំងរង្វាន់ណូបែលសន្តិភាពនៅឆ្នាំ១៩៩១ផងដែរ។ សព្វថ្ងៃ អ្នកស្រីមានអាយុ ៦៣ឆ្នាំហើយ។**

នៅឆ្នាំ១៩៤០ កងទ័ពឯករាជ្យភូមា ដែលត្រូវបានបង្កើតឡើងដោយលោកអ៊ុង សាន ក៏បានទៅហ្វឹកហ្វឺននៅប្រទេសជប៉ុន ។ កងទ័ពនេះក៏ប្រយុទ្ធរហូតដល់ឆ្នាំ១៩៤៤ រួមនឹងជប៉ុនដែលគ្រប់គ្រងប្រទេសភូមា បន្ទាប់មកក៏ត្រឡប់មកប្រឆាំងនឹងជប៉ុនវិញដោយជួយគាំទ្រអង់គ្លេសវិញ ។ ប្រទេសភូមា បានទាមទារនូវឯករាជ្យពីប្រទេសអង់គ្លេសនៅដំណាក់សង្គ្រាមលោកលើកទី២ ។ នាឆ្នាំ១៩៤៧ លោកអ៊ុងសាន ដឹកនាំចលនាទទួលបានឯករាជ្យ ប៉ុន្តែត្រូវគេលួចធ្វើឃាត ។ របបប្រជាធិបតេយ្យអាស្រ័យសភាដែលគ្រប់គ្រងប្រទេសបន្ត មិនអាចឈានដល់ការបង្រួបបង្រួមប្រទេសដែលបែកបាក់នោះឡើយ ។

នៅឆ្នាំ១៩៦២ ក៏មានរដ្ឋប្រហារយោធាមួយរបស់លោកឧត្តមសេនីយ៍នេ វីន នៅក្នុងគោលដៅបញ្ចប់ភាពគ្មានសណ្តាប់ ។ លោកបានដាក់ចេញនូវកំណែទម្រង់សង្គមសំខាន់ៗ ។ នាឆ្នាំ១៩៨៨ មានបាតុកម្មប្រឆាំងនឹងស្ថានភាពនយោបាយ និងសេដ្ឋកិច្ច ប៉ុន្តែត្រូវបានបង្ក្រាបដោយការបង្ហូរឈាម ។ ទោះបីជាយ៉ាងណា វាក៏បានតម្រូវឱ្យរបបយោធារៀបចំការបោះឆ្នោតមួយ ។ គណបក្សប្រឆាំងដឹកនាំដោយកូនស្រីរបស់លោកអ៊ុងសានទទួលជ័យជម្នះ ។ ក្រោយពីមានរដ្ឋប្រហារថ្មីមួយ ក្រុមយោធាលុបចោលនូវលទ្ធផលបោះឆ្នោត ហើយក៏ដាក់ប្រទេសជាតិស្ថិតនៅក្រោមការគ្រប់គ្រងដោយយោធា ។

February-2009.qxd 1/24/2009 4:39 PM Page 16

# ល្បែងកំសាន្ត

## ល្បែងចម្រុះ



### ខ្យល់ធ្វើឱ្យតួអក្សររប៉ាត់រប៉ាយ

សូមប្អូនរកពាក្យដែលសរសេរនៅលើប៉េងប៉ោងទាំងនេះ ដោយដាក់តួអក្សរជាសញ្ញាសម្គាល់កុមារនីមួយៗ ស្របតាមតួអក្សរនៅលើប៉េងប៉ោង ដែលកុមារទាំងនោះកំពុងកាន់។

### ស្រមោលលាយឡំគ្នា

អ្នករាំទាំងអស់កំពុងតែបាត់ស្រមោលរបស់ខ្លួនហើយ។ សូមប្អូនជួយរកស្រមោលឱ្យគាត់វិញផង។ ប្រយ័ត្ន! មានអ្នករាំម្នាក់គ្មានស្រមោលទេ។




ចម្លើយ : ទំព័រ៣

សូមថ្លែងអំណរគុណដល់អង្គការស៊ីប៉ាដែលជួយឧបត្ថម្ភទំព័រនេះ។

អង្គការស៊ីប៉ា : ប្រអប់សំបុត្រ ៣១ ផ្ទះលេខ៩ ផ្លូវ២១ រាជធានីភ្នំពេញ-កម្ពុជា ឬទូរស័ព្ទ : ០២៣ ២១៦ ០០១។

# កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក"

ជាកម្មវិធីមួយដែលរៀបចំឡើងដោយការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក ក្នុងការបង្ហាញផ្លូវ និងរកដំណោះស្រាយដល់មិត្តយុវវ័យ មានដូចជា បញ្ហាសង្គម ចិត្តសាស្ត្រ និងទំនាក់ទំនងយុវវ័យ-ល-។ កម្មវិធីនេះមានការផ្សាយផ្ទាល់រាល់ថ្ងៃច័ន្ទ និងអង្គារ វេលាម៉ោង ១០-១១ព្រឹក នៅវិទ្យុគ្រួសារ **FM 99.5 Mhz** រាជធានីភ្នំពេញ។

# ការងារប្រចាំខែ

- ដើមខែកុម្ភៈ : មានការជួសជុលផ្ទះជូនអ្នកក្រីក្រនៅភ្នំពេញ ឧបត្ថម្ភដោយសប្បុរសជនមកពីអង់គ្លេស បារាំង និងកម្ពុជា។
- ថ្ងៃទី៣-៦ ខែកុម្ភៈ : សំណាក់ធម៌ជំហានទី២ ចំនួន១៨នាក់ នៅព្រះសហគមន៍កោះរកា និយាយអំពីអគ្គសញ្ញាជ្រមុជទឹក លាបថ្វាស និងទទួលព្រះកាយព្រះគ្រីស្ត។
- ថ្ងៃទី៩ ខែកុម្ភៈ : ប្រជុំក្រុមយុវជនស្តីពីជីវិតរបស់គ្រីស្តទូតប៉ូល នៅកំពង់ចាម។
- ថ្ងៃទី១០-១២ ខែកុម្ភៈ : ក្រុមបងស្រីឧបការគុណនៅភ្នំពេញទៅសំណាក់ធម៌នៅព្រះសហគមន៍កំពង់ចាម និងកោះរកា។
- ថ្ងៃទី១៤-១៥ ខែកុម្ភៈ : សិក្ខាសាលាក្រុមយុវជនយុវនារីភូមិភាគភ្នំពេញ ស្តីអំពីការឆ្លុះបញ្ចាំងខ្លួនឯង និងបេសកកម្មរបស់យុវជនក្នុងព្រះសហគមន៍ នៅចំប៉ា ភូមិភាគភ្នំពេញ។
- ថ្ងៃទី១៥ ខែកុម្ភៈ : ប្រជុំក្រុមវាំងសង់ ឪប៉ូល ចំនួន ១៥ក្រុម និយាយពីលទ្ធផលដែលបានធ្វើកន្លងមក នៅភ្នំពេញ។
- ថ្ងៃទី១៨-២២ ខែកុម្ភៈ : ក្រុមគ្រីស្តបរិស័ទមកពីប្រទេសអង់គ្លេស អូស្ត្រាលី និងសិង្ហបុរីចុះសួរសុខទុក្ខបងប្អូនព្រះសហគមន៍នៅខេត្តសៀមរាប ព្រែកទាល់ ចុងឃ្នាស និងពាក់ស្នែង ដោយមាននាំយកនូវអំណោយ និងការជួសជុលផ្ទះ ជូនអ្នកក្រីក្រទៀតផង។
- ថ្ងៃទី២១-២២ ខែកុម្ភៈ : សិក្ខាសាលាក្រុមយុវជនយុវនារីភូមិភាគភ្នំពេញ ស្តីអំពីការឆ្លុះបញ្ចាំងខ្លួនឯង និងបេសកកម្មរបស់យុវជនក្នុងព្រះសហគមន៍នៅមណ្ឌលសកម្មភាពតាកែវ។
- ថ្ងៃទី២៤ ខែកុម្ភៈ : ប្រជុំក្រុមប្រឹក្សាណែនាំព្រះសហគមន៍ភូមិភាគកំពង់ចាម រិះគិតអំពីជីវិតព្រះសហគមន៍ក្នុងភូមិភាគកំពង់ចាម។
- ថ្ងៃ២៨ កុម្ភៈ ដល់ថ្ងៃទី០១ មីនា : សិក្ខាសាលាក្រុមយុវជនយុវនារីភូមិភាគភ្នំពេញ ស្តីអំពីការឆ្លុះបញ្ចាំងខ្លួនឯង និងបេសកកម្មរបស់យុវជនក្នុងព្រះសហគមន៍ នៅមណ្ឌលសកម្មភាពបឹងទំពុនរាជធានីភ្នំពេញ។
- នៅចុងខែកុម្ភៈ : ប្រជុំមនុស្សចាស់ ៣០នាក់ នៅព្រះសហគមន៍កាតូលិកតាអំ ខេត្តសៀមរាប លើប្រធានបទ "ជីវិតរស់នៅក្នុងព្រះសហគមន៍ និងក្នុងសង្គម"។
- ថ្ងៃទី០១ ខែមីនា : ជំហានទី២ នៅព្រះសហគមន៍កំពង់ចាមចំនួន ១៨នាក់។